# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

(អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

# ឯកសារស្តីអំពី

# សកម្មភាពកុមារជួយកុមារ



**អង្គការខេប (KAPE)**

**ខែមករា ឆ្នាំ ២០០៧**

# សកម្មភាពកុមារជួយកុមារ

## I. **សេចក្តីផ្តើម :**

ឯកសារនេះសម្រាប់ជាជំនួយដល់គ្រូប្រចាំថ្នាក់ ដែលមានបំណងក្នុងការរៀបចំសកម្មភាព កុមារជួយកុមារ ដើម្បីបង្កឱ្យសិស្សចេះជួយគ្នាទៅវិញទៅមកក្នុងពេលសិក្សានៅក្នុងសាលារៀននិងនៅក្នុងសហគមន៍ ។ការសិក្សាតាមរយៈការជួយគ្នា នៅក្នុងឯកសារនេះ មានន័យថា:

- សិស្ស២នាក់ ឬច្រើននាក់ រៀនឬត្រូវធ្វើកិច្ចការដែលគ្រូដាក់ឱ្យឬកិច្ចការផ្សេងទៀតជាមួយគ្នា(Lerner2000) ។
- សិស្ស២នាក់ ឬច្រើននាក់ជួយសិស្សពិការ ឱ្យបានមករៀននិងរៀនជាមួយគ្នា ។
- សិស្ស២នាក់ ឬច្រើននាក់ជួយសិស្សដែលមានអវត្តមានច្រើន ឱ្យបានមករៀន និងរៀនជាមួយគ្នា ។

សរុបសេចក្តីមក សកម្មភាពកុមារជួយកុមារ មានគោលបំណងចង់ឱ្យកុមារចេះយល់ចិត្តគ្នា ចេះយកអាសាគ្នា ចេះជួយគ្នា ចេះគ្រប់គ្រងគ្នាគ្រប់កាលៈទេសៈ ហើយនឹងមិនរើសអើងដោយមិនប្រកាន់ថាអ្នកក្រ ឬអ្នកមាន អ្នករៀនពូកែ ឬអ្នករៀនខ្សោយ អ្នកមានកាយសម្បទាល្អ ឬពិការឡើយ ។ ដូច្នេះក្នុងឯកសារនេះគឺយើងបានរៀបចំជា៥ សកម្មភាពគឺ :

១- ការជួយកុមារថ្នាក់ទី១ និងថ្នាក់ទី២ ឱ្យចេះអាន និងចេះសរសេរ ។
២- ការជួយសិស្សថ្នាក់ទី ៦ ពីរបៀបសរសេរសំបុត្ររកមិត្តភក្តិ ។
៣- ការជួយសិស្សថ្នាក់ទី៤ ទី៥ និងថ្នាក់ទី៦ ក្នុងការរៀបចំក្លឹបសិក្សានៅផ្ទះ ។
៤- ការជួយសិស្សពិការ ( ដៃ.ជើង. ភ្នែក.ត្រចៀក ) ។
៥- ការជួយសិស្សអវត្តមានច្រើន ។

## II. **គោលបំណង**

- សិក្ខាកាមកំណត់បានអំពីសារៈសំខាន់នៃសកម្មភាពកុមារជួយកុមារ ។
- សិក្ខាកាមកំណត់បានសកម្មភាព ជួយកុមារថ្នាក់ទី១ និង ទី២ ឱ្យចេះអាន និងចេះសរសេរ ។
- សិក្ខាកាមកំណត់បានសកម្មភាពជួយសិស្សថ្នាក់ទី៦ក្នុងការសរសេរសំបុត្ររកមិត្តភក្តិនៅសាលារៀនផ្សេងទៀត
- សិក្ខាកាមកំណត់បានសកម្មភាពជួយសិស្សថ្នាក់ទី៤ ទី៥ និង ថ្នាក់ទី៦ ក្នុងការរៀបចំក្លឹបសិក្សា ។
- សិក្ខាកាមកំណត់បានសកម្មភាពជួយដល់សិស្សពិការ (ភ្នែក ត្រចៀក ដៃ ជើង )ឱ្យបានចូលរៀន និងរៀនប្រកបដោយក្តីសប្បាយរីករាយ និងមានប្រសិទ្ធភាព ។
- សិក្ខាកាមកំណត់បានសកម្មភាពជួយសិស្សអវត្តមានច្រើនឱ្យបានមករៀនទៀងទាត់ ។

## III. **រយៈពេល**

- សិក្ខាសាលា រយៈពេល ២ ថ្ងៃ

## IV. **សម្ភារ**

- ក្រដាសផ្ទាំងធំ

- ក្រដាសវ៉ាម A 4
- ក្តារខៀន ស
- រូបថតសកម្មភាពទាំង៥ ( សកម្មភាពកុមារជួយកុមារ )
- ឯកសារឧបសម្ព័ន្ធ ក :មេរៀនសម្រាប់ជួយកុមារ ឱ្យចេះអាន និង ចេះសរសេរ ( សិក្ខាកាមម្នាក់មួយ ១ ) ។
- ឯកសារឧបសម្ព័ន្ធ ខ : មេរៀនសម្រាប់ជួយកុមារ ឱ្យចេះសរសេរសំបុត្ររកមិត្តភក្តិ( សិក្ខាកាមម្នាក់មួយ១ ) ។
- ឯកសារឧបសម្ព័ន្ធ គ : មេរៀនសម្រាប់ជួយកុមាររៀនក្នុងក្លឹបសិក្សានៅផ្ទះ ( សិក្ខាកាមម្នាក់មួយ ១ ) ។
- ឯកសារឧបសម្ព័ន្ធ ឃ :មេរៀនសម្រាប់ជួយកុមារពិការដៃ ជើង ( សិក្ខាកាមម្នាក់មួយ ១ ) ។
- ឯកសារឧបសម្ព័ន្ធ ង : មេរៀនសម្រាប់ជួយកុមារមានបញ្ហាភ្នែក ( សិក្ខាកាមម្នាក់មួយ ១ ) ។
- ឯកសារឧបសម្ព័ន្ធ ច : មេរៀនសម្រាប់ជួយកុមារមានបញ្ហាត្រចៀក ( សិក្ខាកាមម្នាក់មួយ ១ ) ។
- ឯកសារឧបសម្ព័ន្ធ ឆ : មេរៀនសម្រាប់ជួយកុមាររៀនមានអវត្តមានច្រើន ( សិក្ខាកាមម្នាក់មួយ ១ ) ។

V- **វិធីសាស្ត្រ** : សិក្ខាកាមជាមជ្ឈមណ្ឌល

VI- **អ្នកចូលរួម** : លោកនាយកសាលា គ្រូស្ម័គ្រចិត្ត២នាក់ក្នុងមួយសាលា

## VII- **ដំណាក់កាលក្នុងការសម្របសម្រួល**

- ការណែនាំខ្លួន និងបង្ហាញពីគោលបំណងរបស់សិក្ខាសាលា ( ១០នាទី )

### I. **ការជួយសិស្សថ្នាក់ទី១ និងទី២ឱ្យចេះអាន និងសរសេរ (៣ម៉ោង )**

អ្នកសម្របសម្រួលពន្យល់ថា សកម្មភាពកុមារជួយកុមារពិតជាមានអត្ថប្រយោជន៍ ដើម្បីជួយសិស្សថ្នាក់ទី១ និងថ្នាក់ទី២ ដែលជួបការលំបាកក្នុងការអាន និងសរសេរ ។ ភាសាខ្មែរគឺជាមុខវិជ្ជាមួយដ៏សំខាន់បំផុត ដើម្បីឈានទៅរៀនមុខវិជ្ជាផ្សេងទៀតដូចជា : គណិតវិទ្យា .វិទ្យាសាស្ត្រអនុវត្ត និងសិក្សាសង្គម ។ សិស្សត្រូវតែមានបំណិនជាមូលដ្ឋានលើមុខវិជ្ជាភាសាខ្មែរ ។ វាជាសារៈសំខាន់ណាស់ ដែលយើងត្រូវជួយធ្វើការហ្វឹកហាត់ភាសាដល់ពួកគេឱ្យបានជារៀងរាល់ថ្ងៃ ។ ការរៀបចំសិស្សថ្នាក់ទី១ និងថ្នាក់ទី២ ជាគូនឹងសិស្សថ្នាក់ទី៥ និងថ្នាក់ទី៦ គឺសិស្សនៅថ្នាក់ធំនេះអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការជួយសិស្សរៀននៅថ្នាក់ទាប ដែលជួបការលំបាកក្នុងការអាន និងសរសេរ ។ សាលារៀនទីមួយៗមានសិស្សរៀននៅថ្នាក់ទី១ និងថ្នាក់ទី២ជាច្រើនដែលជួបការលំបាកក្នុងការអាន និងសរសេរ នេះគឺជាមូលហេតុដែលសកម្មភាពកុមារជួយកុមារ ត្រូវតែចាប់អារម្មណ៍ទៅលើកុមារណាដែលមាន បញ្ហាលើ ការអាន និងសរសេរ លើមុខវិជ្ជាភាសាខ្មែរ ។

- អ្នកសម្របសម្រួលចែកក្រដាសផ្ទាំងធំ ហ្វឺត និងដាក់សំណួរឱ្យសិក្ខាកាមពិភាក្សា ដូចខាងក្រោម :

- តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដើម្បីកំណត់សិស្សថ្នាក់ទី១ និងថ្នាក់ទី២ ដែលមានការលំបាកក្នុងការអាន ?

  ចម្លើយ :

  ក- សិស្សដែលតែងតែអានអក្សរខុស ។

  ខ- សិស្សដែលមិនចំណាំអក្សរ ។

  គ- សិស្សដែលផ្សំពាក្យខុសរវាងព្យញ្ជនៈ អ និង អ៊ ។

  ឃ- សិស្សដែលមិនអាចអានពាក្យធម្មតាបាន......។ល។

- តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដើម្បីកំណត់សិស្សថ្នាក់ទី១ និងថ្នាក់ទី២ដែលមានការលំបាកក្នុងការសរសេរ ?

ចម្លើយ

ក-　សិស្សដែលតែងតែសរសេរពាក្យខុស ។

ខ-　សិស្សដែលពុំទាន់ស្គាល់ពីរបៀបសរសេរអក្សរ ។

គ-　សិស្សដែលមិនអាចសរសេរពាក្យធម្មតាបាន....។ល ។

- អ្នកសម្របសម្រួលបញ្ជាក់បន្ថែមទៀតថា គ្រូថ្នាក់ទី១ និងថ្នាក់ទី២ គួរតែជ្រើសរើសសិស្សណាដែលមានបញ្ហាតាមលក្ខណៈវិនិច្ឆ័យនេះ ។ចំពោះគ្រូថ្នាក់ទី៥ និងថ្នាក់ទី៦ត្រូវជ្រើសរើសសិស្សរបស់គេផងដែរ ដើម្បីចូលរួមក្នុងសកម្មភាពជួយសិស្សថ្នាក់ទី១ និងថ្នាក់ទី២ ឱ្យចេះអាន និងចេះសរសេរ ។

- តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដើម្បីកំណត់សិស្សនៅថ្នាក់ទី៥ និងថ្នាក់ទី៦ ឱ្យចូលរួមក្នុងសកម្មភាពជួយសិស្សថ្នាក់ ទី១ ឬទី២ ដែលជួបការលំបាកអាន និងសរសេរ ?

<u>ចម្លើយ</u> :

ក- សិស្សស្ម័គ្រចិត្ត ។

ខ- សិស្សដែលមានពេលវេលាគ្រប់គ្រាន់ក្នុងការផ្តល់ជំនួយ ។

គ- សិស្សដែលចាប់អារម្មណ៍ជាមួយការងាររបស់កុមារតូចៗ ។

ឃ- សិស្សឧស្សាហ៍ព្យាយាម និងចេះអត់ធ្មត់ ...។ល។

ង- សិស្សមានចរិតស្លូតបូត សុភាពរាបសារ។

- អ្នកសម្របសម្រួលពន្យល់ថាដើម្បីឱ្យសកម្មភាពជួយកុមារថ្នាក់ទី១ និងទី២ឱ្យចេះអាន និងចេះសរសេរមានដំណើរការទៅប្រកបដោយប្រសិទ្ធភាព ។ ចំពោះគ្រូថ្នាក់ទី៥ និងថ្នាក់ទី៦ត្រូវបង្រៀនសិស្សរបស់ខ្លួននូវមេរៀនមួយ អំពីការជួយកុមារតូចៗ ឱ្យចេះអាន និង ចេះសរសេរ។
- អ្នកសម្របសម្រួលចែកឧបសម្ព័ន្ធ ក ទៅឱ្យសិក្ខាកាម រួចឱ្យសិក្ខាកាមណាមួយអានឮ ឯសិក្ខាកាមផ្សេងទៀតអានស្ងាត់ ។

- តើសកម្មភាពនៃការអាន និងសរសេរ អាចធ្វើឡើងនៅឯណា ? និងនៅពេលណា ?

**<u>ចម្លើយ</u>**

ក- បណ្ណាល័យ ។

ខ- បន្ទប់រៀន ។

គ- ក្រៅបន្ទប់រៀន ។

ឃ- នៅក្រោមដើមឈើ ។

ង- . . . .។ ល ។

**<u>ចម្លើយ</u>**

ក- ពេលចេញលេង ។

ខ- មុនពេលចូលរៀន ។

គ- . . ។ល។

អ្នកសម្របសម្រួលពន្យល់ទៀតថារយៈពេលមួយសប្តាហ៍ បន្ទាប់ពីបង្រៀនមេរៀនដល់សិស្សថ្នាក់ទី៥ និងសិស្សថ្នាក់ទី៦រួចគឺសិស្សថ្នាក់ទី៥និងសិស្សថ្នាក់ទី៦ត្រូវជាគូជាមួយសិស្សថ្នាក់ទី១និងសិស្សថ្នាក់ទី២ ។សកម្មភាពនេះត្រូវបានធ្វើឡើងនៅសាលារៀន ហើយចំពោះសិស្សទាំងអស់ដែលបានជ្រើសរើស និងគ្រូរបស់គេត្រូវមកចូលរួមជាមួយគ្នានៅក្នុងបន្ទប់ណាមួយ ។ សិស្សត្រូវណែនាំពីខ្លួនគេដោយខ្លីៗដល់គ្នាទៅវិញទៅមក (ណែនាំឈ្មោះនិងភូមិ) ។បន្ទាប់មកទៀតចំពោះឈ្មោះសិស្សថ្នាក់ទី១ និងថ្នាក់ទី២ត្រូវសរសេរដាក់ក្នុងប្រអប់មួយហើយសិស្សថ្នាក់ទី៥ និងថ្នាក់ទី៦ត្រូវសរសេរឈ្មោះដាក់នៅក្នុងប្រអប់មួយផ្សេងទៀត រួចគ្រូអាចយកឈ្មោះមួយចេញពីប្រអប់នីមួយៗ ឈ្មោះសិស្សដែលគ្រូបានហៅត្រូវជាគូគ្នា គឺគេទាំងពីរត្រូវអង្គុយក្បែរគ្នា រួចណែនាំគ្នាទៅវិញទៅមក ។ គ្រូចែកសៀវភៅអានទៅសិស្ស រួចអនុញ្ញាតឱ្យសិស្សថ្នាក់ទី១ និងថ្នាក់ទី២ អានរយៈពេល ១៥នាទី ជាមួយដៃគូរបស់គេនៅថ្នាក់ទី៥ និងថ្នាក់ទី៦ ។ មុនពេលបែកគ្នា គូនីមួយៗ ត្រូវតែធ្វើការណាត់ជួបគ្នាដើម្បីអាន ឬសរសេរជាមួយគ្នាម្តងទៀត ( ថ្ងៃ ពេលវេលា និងទីកន្លែងនៅសាលា ) ។

- <u>កំណត់សម្គាល់</u> : ប្រសិនបើសាលាណារៀន២ពេល ចំពោះសិស្សដែលរៀននៅពេលព្រឹក ត្រូវតែបំបែកចេញពីសិស្សរៀននៅពេលរសៀល ។ ធ្វើបែបនេះគឺអាចជៀសវាងកុមារ ដែលរៀនព្រឹកមានគូជាមួយកុមារដែលរៀនពេលរសៀល ។
- អ្នកសម្របសម្រួលពន្យល់ថាៈ វាពិតជាមានសារៈសំខាន់ ដែលគ្រូត្រូវត្រួតពិនិត្យទៅលើសិស្សរបស់គេឱ្យបានទៀងទាត់ជាពិសេសនៅពេលចាប់ផ្តើមនិងនៅពេលកំពុងធ្វើសកម្មភាព គ្រូត្រូវតែជួយសិស្សក្នុងការហាត់អានព្រមទាំងការហាត់សរសេររបស់ ពួកគេ ។
- អ្នកសម្របសម្រួលទុកឱកាសឱ្យសិក្ខាកាមពិភាក្សាយ៉ាងខ្លី អំពីប្រភេទលំហាត់គួរត្រួតពិនិត្យ ដែលអាចមាននៅក្នុងសាលា ។

## II . ការជួយសិស្សក្នុងការសរសេរសំបុត្ររកមិត្តភក្តិ :

- អ្នកសម្របសម្រួលពន្យល់ថា ការសរសេរសំបុត្រគឺជាការប្តូរសំបុត្រគ្នាទៅវិញទៅមក រវាងសិស្សនៅសាលារៀនមួយទៅសាលារៀនមួយទៀត ។ ការសរសេរសំបុត្រគឺជាបំណិនមួយ ដែលអាចបង្កើនចំណេះដឹងរបស់សិស្សតាមរយៈការអនុវត្តជាក់ស្តែង ម្យ៉ាងទៀតអាចជួយសិស្សឱ្យមានគំនិតយោបល់ច្រើន ដើម្បីជួយដល់មិត្តរបស់ពួកគេពីអ្វីដែលគេកំពុងទទួលបានជោគជ័យទាំងការសិក្សា និងការចូលរួមចំណែកជួយការងារឪពុកម្តាយរបស់គេ ពិសេសទៅទៀតពួកគេបានយល់ដឹងបន្ថែមទៀតអំពីជីវភាពមិត្តរបស់គេដែលរស់នៅក្រៅភូមិស្រុក និងក្រៅខេត្តទៀតផង ។ ការសរសេរសំបុត្ររកមិត្តភក្តិគឺតម្រូវឱ្យមានកម្រិតជំនាញមួយពិតប្រាកដ ហេតុនេះហើយយើងសូមជូនជាយោបល់ថា សកម្មភាពនេះត្រូវបានអនុវត្តសម្រាប់ថ្នាក់ទី៦ ប៉ុណ្ណោះ ។ គោលបំណងរបស់សកម្មភាពនេះ គឺយើងចង់ឱ្យសិស្សថ្នាក់ទី៦ចូលរួមសរសេរសំបុត្របានទាំងអស់គ្នា តែយើងត្រូវដឹងថា

សិស្សមួយចំនួនមិនអាចសរសេរដោយគ្មានត្រូវការជំនួយពីគេបានឡើយ ។ ដូច្នេះយើងគួរតែរកសិស្ស ដែលត្រូវការជំនួយទាំងនោះឱ្យឃើញសិន មុនពេលយើងធ្វើសកម្មភាពនេះ ។

- តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះដើម្បីកំណត់សិស្សថ្នាក់ទី៦ ដែលត្រូវការជំនួយក្នុងការសរសេរសំបុត្ររកមិត្តភក្តិ ?

<u>ចម្លើយ</u>

ក- ការសិក្សាមុខវិជ្ជាភាសាខ្មែរ បានពិន្ទុក្រោមមធ្យមភាគ ។

ខ- សរសេរយឺត ។

គ- ខ្សោយផ្នែកសំណេរតែងសេចក្តី ។

ឃ- ពិបាកអាន និងពិបាកសរសេរអក្សរ ។

ង- . . . ។ល។

- អ្នកសម្របសម្រួលពន្យល់ទៀតថាគ្រូថ្នាក់ទី៦គួររៀបចំសិស្សជាគូ ដោយដាក់សិស្សដែលពូកែជាមួយសិស្សខ្សោយ ដើម្បីជួយសម្រួលឱ្យសិស្សខ្សោយបានចូលរួមក្នុងការសរសេរសំបុត្រនេះ ដោយមិនពន្យល់ពីមូលហេតុដែលអ្នករៀបចំសិស្សដាក់ជាគូនេះទេ ហើយមិនត្រូវដាក់ឈ្មោះចំពោះសិស្សណាមួយជាសិស្សខ្សោយឡើយ (ជៀសវាង ការរើសអើង ) ។

- អ្នកសម្របសម្រួលចែកឧបសម្ព័ន ខ ទៅឱ្យសិក្ខាកាម ។

## III . **ការរៀបចំក្លឹបសិក្សានៅផ្ទះ**

- អ្នកសម្របសម្រួលពន្យល់ថា ក្លឹបសិក្សាគឺជាសកម្មភាពមួយ ដែលសិស្សអាចជួបគ្នាក្នុងពេលទំនេរនៅកន្លែងណាមួយ ឬនៅក្នុងសហគមន៍របស់ពួកគេ ។ ក្នុងក្លឹបសិក្សានេះ ត្រូវបានរៀបចំដោយជ្រើសយកសិស្សម្នាក់ក្នុងមួយថ្ងៃ ជាអ្នកសម្របសម្រួល ហើយសិស្សផ្សេងទៀតជាអ្នកដាក់បញ្ហាផង ហើយក៏ជាអ្នកដោះស្រាយបញ្ហាផងដែរ និងបញ្ហាខ្លះទៀត ត្រូវបានរៀបចំដោយគ្រូប្រចាំថ្នាក់សម្រាប់កិច្ចការក្លឹបរបស់ពួកគេ ។ ក្លឹបសិក្សានៅផ្ទះអាចបង្កលក្ខណៈឱ្យសិស្សចេះជួយខ្លួនឯងផង ព្រមទាំងជួយដល់សិស្សដែលមានវ័យស្របាលគ្នាផង ។ ចំពោះសិស្សដែលរៀនយឺតពួកគេនឹងទទួលបាននូវចំណេះដឹងបន្ថែមតាមរយៈការអនុវត្តផ្ទាល់ទៅលើ លំហាត់ដែលបានរៀនរួច ។ ដូច្នេះសកម្មភាពនេះ អាចជួយបង្កើនអត្រាឡើងថ្នាក់ ដល់សិស្សដែលរៀនយឺតផង និងបង្កើនសមត្ថភាព ដល់សិស្សដែលរៀនបានល្អប្រសើរឱ្យកាន់តែខ្ពស់ឡើងថែមទៀត ។ ជាធម្មតាគ្រូពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីជួយបង្រៀន ឬជួយរំលឹកមេរៀនចាស់ ដែលសិស្សមួយចំនួនត្រូវការនោះបានគ្រប់តម្រូវការឡើយ ។ ដូច្នេះដើម្បីបំពេញតម្រូវការនេះដល់ពួកគេគឺមានតែវិធីរៀបចំក្លឹបសិក្សានៅផ្ទះទេ ដែលអាចជួយដល់ពួកគេបាន ។ ក្លឹបសិក្សានេះគឺផ្តោតលើមុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យា ។

- អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថាៈក្លឹបសិក្សានេះអាចធ្វើបានគ្រប់កម្រិតថ្នាក់ទាំងអស់ ក៏ប៉ុន្តែនៅក្នុងការសាកល្បងគួរធ្វើនៅថ្នាក់ទី ៤ ទី៥ និងថ្នាក់ទី៦សិន ។

- តើសិស្សស្ថិតក្នុងស្ថានភាពបែបណាដែលសាលារៀនត្រូវជួយជំរុញឱ្យចូលរួមក្នុងក្លឹបសិក្សា ?

**ចំលើយ**

ក- សិស្សដែលមានអវត្តមានច្រើន ។

ខ- សិស្សរៀនខ្សោយលើមុខវិជ្ជា ភាសាខ្មែរ និង គណិតវិទ្យា ។

គ- សិស្សក្រីក្រ ។

ឃ- សិស្សមានសេចក្តីប្រថុយក្នុងការបោះបង់ ។

ង- សិស្សពិការ ។

អ្នកសម្របសម្រួលគួរបញ្ជាក់បន្ថែមទៀតថាគ្រូថ្នាក់ទី៤ទី៥ និងថ្នាក់ទី៦ គួរតែជួយជំរុញនិងលើកទឹកចិត្តសិស្ស ដែលមានលក្ខណៈវិនិច្ឆ័យដូចខាងលើឱ្យចូលរួមក្នុងក្លឹបសិក្សានៅផ្ទះ ។

- អ្នកសម្របសម្រួលចែកឧបសម្ព័ន្ធ គ ទៅឱ្យសិក្ខាកាម រួចអានមេរៀនជាមួយសិក្ខាកាម ។

- តើយើងកំណត់កន្លែងបែបណា ដើម្បីផ្តល់ភាពងាយស្រួលដល់សិស្សដែលចូលរួមក្នុងក្លឹបសិក្សា?

**ចំលើយ**

ក- កន្លែងដែលជាចំណុចកណ្តាល នៃសិស្សទាំងអស់ក្នុងក្លឹប ។

ខ- កន្លែងទូលាយដែលបង្កលក្ខណៈឱ្យសិស្សអង្គុយរៀនស្រួល ។

គ- កន្លែងដែលឆ្ងាយពីកន្លែងដែលបង្កសម្លេងរំខាន ( ផ្ទះធ្វើម៉ាញ៉េ មីក្រូ ម៉ាស៊ីនកិនស្រូវ ...។ល។ )

ឃ- កន្លែងដែលមិនក្តៅ ។

- ដើម្បីរៀបចំក្លឹបសិក្សា ឱ្យមានដំណើរការបានល្អ តើត្រូវការសម្ភារអ្វីខ្លះ?

**ចំលើយ**

ក- ក្តារខៀន ។

ខ- តុ ( តាមលទ្ធភាពដែលអាចធ្វើបាន ) ។

គ- កន្ទេល ។

ឃ- សៀវភៅសរសេរ សៀវភៅពុម្ព ប៊ិច ដីស ហ្វឺត ...។ល។

- អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា ដើម្បីឱ្យក្លឹបសិក្សាមានដំណើរការបានល្អ មុនពេលចាប់ផ្តើមដំណើរការលោកគ្រូ អ្នកគ្រូគប្បីឱ្យក្រុមក្លឹបនីមួយៗយល់ដឹងឱ្យបានច្បាស់ពីដំណើរការខ្លឹបសិក្សា ពីដំបូងរហូតដល់ពេលបញ្ចប់ក្លឹប ។ ចំពោះប្រធានក្រុមនីមួយៗ ត្រូវឱ្យពួកគេចេះគ្រប់គ្រងសកម្មភាពក្លឹបទាំងដំណើរការក្លឹប និងវិន័យក្នុងពេលសិក្សា ។

## IV. ការជួយកុមារពិការ

### ៤.១ ការជួយសិស្សពិការជើង

- អ្នកសម្របសម្រួលពន្យល់ថា កុមារពិការជើងមួយចំនួនមិនទាន់បានចូលរៀន ឯមួយចំនួនទៀតបានចូលរៀនហើយ ។ ជារឿយៗកុមារពិការជើងទាំងឡាយដែលបានចូលរៀនហើយ តែងតែមានអវត្តមានច្រើន ហើយមាន

សេចក្តីប្រថុយនឹងការបោះបង់ទៀត ។ ជាក់ស្តែងកុមារពិការជើងមួយចំនួនបានឈប់រៀន ដែលការសិក្សារបស់ពួកគេពុំទាន់បានរៀនចប់ថ្នាក់នៅបឋមសិក្សាផង។ ថ្ងៃអនាគត ពួកគេប្រាកដជាជួបការលំបាកកាន់តែធ្ងន់ធ្ងរទៅៗ នេះជាមូលហេតុដែលសកម្មភាពកុមារជួយកុមារត្រូវតែចាប់អារម្មណ៍ និងយកចិត្តទុកដាក់ដល់កុមារពិការជើងទាំងនោះឱ្យបានចូលរៀន និង រៀនបានទៀងទាត់ដូចកុមារដទៃទៀត។

- ទាំងនៅសាលារៀន និងនៅសហគមន៍តើកុមារពិការជើងជួបបញ្ហាអ្វីខ្លះ ?

ចម្លើយ

ក- ពិបាកធ្វើដំណើរទៅ និងមកសាលារៀន ។

ខ- ពុំសូវមានឱកាសបានចូលរួមធ្វើសកម្មភាពផ្សេងៗ ។

គ- ពុំសូវបានចូលរួមលេងល្បែងផ្សេងៗ ។

ឃ- មានអារម្មណ៍ខ្មាស់អៀន ។

ង- មានអារម្មណ៍ភ័យខ្លាច ។

ច- មានការរើសអើង ។

ឆ- គ្មានទំនុកចិត្ត ។

ជ- ភាពក្រីក្រ ។

ឈ- .........។ល។

- តើយើងត្រូវជួយសិស្សពិការជើងលើសកម្មភាពអ្វីខ្លះ ដើម្បីឱ្យពួកគេមានអារម្មណ៍សប្បាយរីករាយក្នុងកាសិក្សា?

<u>**ចំលើយ**</u>

ក- ជួយឱបកង់ទៅ និងមកសាលារៀន ។

ខ- ជួយរុញរទេះទៅ និងមកសាលារៀន ។

គ- ជួយបង្កើតល្បែងដើម្បីឱ្យពួកគេបានលេង និងចូលរួមលេងជាមួយពួកគេ ។

ឃ- ឧស្សាហ៍ទៅលេងផ្ទះកុមារពិការនៅពេលទំនេរ ( តាមលទ្ធភាពដែលអាចធ្វើបាន )

ង - ជួយធ្វើជំរេល ( ប្លង់ទេ ) នៅមុខថ្នាក់សិស្សពិការដែលមានរទេះរុញ ។

ច- ជួយដឹកដៃ ឬជួយរុញរទេះចូលថ្នាក់ ។

ឆ- ជួយសម្រួលកន្លែងអង្គុយរៀនឱ្យបានសមស្រប ។

ជ- មិនធ្វើត្រាប់តាមរាល់ទង្វើផ្សេងៗរបស់សិស្សពិការ ។

ឈ- មិនត្រូវសើចចំអក ។

ញ- ត្រូវធ្វើការលើទឹកចិត្តរាល់ទង្វើដែលពួកគេបានខិតខំធ្វើទាំងការលំបាក ។

ដ- ត្រូវជួយដឹកដៃចូលបន្ទប់ទឹក ឬបង្គន់នៅពេលសិស្សពិការមានតម្រូវការ ។

- អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា:សកម្មភាពខាងលើជាសកម្មភាពជួយកុមារពិការជើង ដែលអាចឱ្យកុមារពិការជើងមានអារម្មណ៍ល្អ និងសប្បាយរីករាយក្នុងការសិក្សា ភ្លេចពីពិការភាពរបស់ខ្លួន ទៅជាការខិតខំរៀនសូត្រ ហើយអាចបន្តការសិក្សាទៅថ្នាក់បន្តបន្ទាប់ប្រកបដោយគុណភាព និងជោគជ័យ ។

  តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដើម្បីកំណត់សិស្សជួយសិស្សពិការជើងបានល្អប្រសើរ ?

  <u>ចម្លើយ</u>

  ក- សិស្សស្ម័គ្រចិត្ត ។

  ខ- សិស្សដែលជាបងប្អូន ឬ ជាសាច់ញាតិនឹងសិស្សពិការជើង ។

  គ- សិស្សដែលមានទីលំនៅក្នុងភូមិជាមួយគ្នា ។

  ឃ- សិស្សរៀនចំរៃនជាមួយគ្នា ។

- អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថាក្រោយពីរើសសិស្សជួយបានហើយលោកគ្រូ អ្នកគ្រូដាក់វេនគ្នា និងធ្វើកាលវិភាគឱ្យពួកគេបានច្បាស់លាស់ដើម្បីឱ្យពួកគេងាយស្រួលក្នុងការធ្វើសកម្មភាពជួយ ។
- ចែកឧបសម្ព័ន្ធ ឃ ទៅឱ្យសិក្ខាកាម រួចអានមេរៀននេះ ជាមួយសិក្ខាកាម ។

## ៤-២ <u>ការជួយសិស្សដែលមានបញ្ហាភ្នែក</u>

- អ្នកសម្របសម្រួលបញ្ជាក់ថា សិស្សដែលមានបញ្ហាភ្នែក ហើយមិនបានទទួលការគាំទ្រពេញលេញពីគ្រូ ឬពីមិត្តរួមថ្នាក់របស់គេទេ គឺធ្វើឱ្យគេជួបការលំបាកក្នុងការសិក្សា និងអាចឱ្យគេរៀនធ្លាក់ថ្នាក់ ឬបោះបង់ចោលសាលារៀន ។ ដូច្នេះសកម្មភាពកុមារជួយកុមារពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីជួយដល់កុមារដែលមានបញ្ហាភ្នែក ។ បែបនេះ យើងអាចបង្កលក្ខណៈឱ្យគេបានរៀនរឹតតែប្រសើរឡើង ។

- តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដើម្បីកំណត់ថាសិស្សនេះមានបញ្ហាភ្នែក ?

  <u>ចម្លើយ</u>

  ក- សិស្សដែលខូចគ្រាប់ភ្នែកម្ខាង ។

  ខ- សិស្សដែលមានភ្នែកឡើងបាយម្ខាង រឺ ទាំងសងខាង ។

  គ- សិស្សដែលមានហូរទឹកភ្នែកជាប្រចាំ ។

  ឃ- សិស្សដែលស្រវាំងមើលឆ្ងាយមិនច្បាស់ ។

  ង- សិស្ស ធ្លាប់មានជម្ងឺភ្នែកខ្លាំងក្លា ។

  ច- សិស្សពាក់វ៉ែនតាមីញ៉ូប ។

  ឆ- ...។ល។

- ដើម្បីឱ្យសិស្សដែលមានបញ្ហាភ្នែកអង្គុយរៀនស្រួល តើយើងត្រូវរៀបចំកន្លែងអង្គុយ និងធ្វើសកម្មភាពដូចម្តេច?

  ក- ឱ្យអង្គុយតុមុខ ។

  ខ- ឱ្យអង្គុយក្បែរទ្វារ ឬបង្អួច ។

គ- ឱ្យអង្គុយកន្លែងដែលមានពន្លឺគ្រប់គ្រាន់ ។

ឃ- កន្លែងដែលងាយស្រួលក្នុងការមើលក្ដារខៀន ។

ង- ត្រូវសរសេរអក្សរនៅក្ដារខៀនឱ្យបានធំៗ ។

ច- ជួយអានអក្សរនៅក្ដារខៀន នៅពេលដែលគេជួបបញ្ហាក្នុងការមើល ។

- អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា ការរៀបចំនិងធ្វើបែបនេះមិនទាន់គ្រប់គ្រាន់ទេ លោកគ្រូ អ្នកគ្រូគួរតែរៀបចំសិស្សម្នាក់ទៀតឱ្យអង្គុយក្បែរដើម្បីជួយបន្ថែមរាល់តម្រូវការជាក់ស្ដែងរបស់កុមារដែលមានបញ្ហាភ្នែក

- អ្នកសម្របសម្រួលចែកឧបសម្ព័ន្ធ ង ទៅឱ្យសិក្ខាកាមរួចអានមេរៀននេះជាមួយសិក្ខាកាម ។

៤-៣ <u>ការជួយសិស្សដែលមានបញ្ហាត្រចៀក</u> ( ថ្លង់ )

- អ្នកសម្របសម្រួលបញ្ជាក់ថាគ្រូភាគច្រើនមិនសូវចាប់អារម្មណ៍ និងមិនបានយកចិត្តទុកដាក់លើសិស្សដែលមានបញ្ហាត្រចៀកទេ ។ សកម្មភាពកុមារជួយកុមារ ពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយសិស្សដែលមានបញ្ហាត្រចៀក ។ សកម្មភាពនេះធ្វើឱ្យសិស្សដែលមានបញ្ហាត្រចៀកបានមករៀន និងរៀនរឹតតែបានល្អប្រសើរ ។

- ដើម្បីកំណត់ថាសិស្សនេះមានបញ្ហាត្រចៀក តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ?

<u>**ចម្លើយ**</u>

ក- សិស្សមានកើតជម្ងឺអំបៅអំបែក ឬ ធ្លាប់កើតជម្ងឺអំបៅអំបែកពីកន្លងមក ។

ខ- សិស្សដែលផ្ទៀងផ្ទាត់ស្ដាប់នៅពេលអ្នកផ្សេងនិយាយ ។

គ- សិស្សដែលជួបបញ្ហានៅពេលសន្ទនា ( ឆ្លើយមកវិញដោយចាកសំណួរ ) ។

- អ្នកសម្របសម្រួលចែកឧបសម្ព័ន្ធ ច ទៅឱ្យសិក្ខាកាម រួចអានមេរៀននេះជាមួយសិក្ខាកាម ។

- តើយើងត្រូវរៀបចំកន្លែង និងធ្វើយ៉ាងដូចម្ដេចដើម្បីឱ្យសិស្សដែលមានបញ្ហាត្រចៀកអង្គុយរៀនស្រួល ?

ក- អង្គុយតុមុខ ។

ខ- អង្គុយក្បែរតុគ្រូ ។

គ- ព្យាយាមឈរពន្យល់នៅក្បែរសិស្សដែលមានបញ្ហាត្រចៀកឱ្យបានញឹកញាប់ ។

ឃ- ជួយបន្ទអំណានពីគ្រូនៅពេលដែលគេជួបបញ្ហាក្នុងការស្ដាប់ ។

- អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថាការរៀបចំនិងធ្វើបែបនេះមិនទាន់គ្រប់គ្រាន់ទេលោកគ្រូអ្នកគ្រូគួរតែរៀបចំសិស្សម្នាក់ទៀតឱ្យអង្គុយក្បែរដើម្បីជួយបន្ថែមរាល់តម្រូវការជាក់ស្ដែងរបស់កុមារដែលមានបញ្ហាត្រចៀក ។

## V.<u>ការជួយសិស្សអវត្តមានច្រើន</u>

- អ្នកសម្របសម្រួលពន្យល់ថា ប្រសិនបើសិស្សមករៀនមានអវត្តមានច្រើន ពួកគេនឹងមិនទទួលបាននូវលទ្ធផលល្អក្នុងការសិក្សាឡើយ ។

- តើសិស្សមានអវត្តមានចំនួនប៉ុន្មានដងឡើងទៅក្នុងមួយខែ ទើបកំណត់ថាជាសិស្សដែលមានអវត្តមានច្រើន?

**ចម្លើយ**

- សិស្សដែលមានអវត្តមានចាប់ពី៤ថ្ងៃឡើងទៅក្នុងមួយខែ ។

- អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថាសិស្សណា ដែលមានបញ្ហាអវត្តមានច្រើនសិស្សនោះប្រាកដជារៀនខ្សោយ រៀនពុំទាន់គេ ធ្វើឱ្យគ្មានអារម្មណ៍ក្នុងការសិក្សា ធុញថប់ក្នុងការសិក្សា រហូតដល់ខ្លាចសាលា ខ្លាចគ្រូ ខ្មាស់មិត្តភក្តិ ទីបំផុតបោះបង់ចោលការសិក្សាទៀតផងក៏សឹងមាន ។

- តើមានមូលហេតុអ្វីខ្លះ ដែលធ្វើឱ្យសិស្សមានអវត្តមានជាញឹកញាប់ ?

**ចម្លើយ**

ក- សិស្សតូចៗហើយមានទីលំនៅឆ្ងាយពីសាលារៀន ។

ខ- ជួយការងារឪពុកម្តាយនៅផ្ទះ ។

គ- ខ្វះការជួយជំរុញកូនឱ្យមករៀន ។

ឃ- ខ្វះការតាមដានការសិក្សារបស់កូន ។

ង- ជាសិស្សក្រីក្រ ។

ច- គេចរៀន ទៅលេងល្បែងផ្សេងៗ ។

ឆ- សិស្សរៀនខ្សោយ ។

ជ- សិស្សពិការ ។

ឈ- សិស្សខ្លាចគ្រូ ។

ញ- .......។ល។

- តើយើងមានវិធីអ្វីខ្លះ ដើម្បីជួយកាត់បន្ថយអវត្តមាន ដល់សិស្សទាំងនោះ ?

**ចម្លើយ**

ក- រៀបចំសិស្សឱ្យជួយឌុបកង់ដល់សិស្សតូចៗ ដែលមានទីលំនៅឆ្ងាយពីសាលារៀន ។

ខ- ប្តូរវេនរៀនឱ្យខុស នឹងពេលជួយការងារឪពុកម្តាយ ( តាមលទ្ធភាពរបស់សាលាដែលអាចធ្វើបាន ) ។

គ- រៀបក្រុមជួយបបួល ឬជួយនាំសិស្សនេះឱ្យមករៀន ។

ឃ- ជួយបង្រៀន ឬជួយជំរុញឱ្យសិស្សនេះបានរៀននៅក្នុងក្លឹបសិក្សា ។

ង- ជួយផ្តល់មេរៀនឱ្យសិស្សនេះបានចម្លងនៅពេលសិស្សនេះអវត្តមាន ។

ច- បង្កើនការទំនាក់ទំនង និងយកចិត្តទុកដាក់ជាមួយសិស្សអវត្តមានច្រើន ។

ឆ- ជួយលើកទឹកចិត្ត

ជ- ផ្តល់ឱកាសឱ្យបានច្រើនរាល់សកម្មភាពសិក្សា និងលេងល្បែងផ្សេងៗ

- អ្នកសម្របសម្រួលចែកឧបសម្ព័ន្ធ **ឆ** ទៅឱ្យសិក្ខាកាម រួចអានមេរៀននេះជាមួយសិក្ខាកាម ។
- អ្នកសម្របសម្រួលបញ្ជាក់បន្ថែមទៀតថា ដើម្បីឱ្យសកម្មភាពកុមារជួយកុមារ ( គ្រប់សកម្មភាពដែលមាននៅ

ក្នុងឯកសារនេះ ) មានដំណើរការបានល្អ លុះត្រាតែមានការចូលរួមពីនាយកសាលា លោកគ្រូ អ្នកគ្រូ និង សិស្សានុសិស្សទាំងអស់ ដោយធ្វើការតាមដានឱ្យបានជាប្រចាំ ព្រមទាំងផ្តល់នូវរបាយការណ៍ ផ្ញើមកខេបឱ្យបាន ទៀងទាត់ ងាយស្រួលដល់បុគ្គលិករបស់ខេប ជួយធ្វើអន្តរាគមន៍បានទាន់ពេលវេលា ។

## ❀ <u>សារៈសំខាន់នៃសកម្មភាពកុមារជួយកុមារ</u>

- អ្នកសម្របសម្រួលរៀបចំសិក្ខាកាមជាក្រុមតូច រួចចែកក្រដាសផ្ទាំងធំ ហ្វឺត និង សួរសំណួរដូចខាងក្រោម :

- តើសកម្មភាពកុមារជួយកុមារផ្តល់នូវសារៈសំខាន់អ្វីខ្លះ ?

<u>ចម្លើយ</u>

ក- សិស្សពិការត្រូវបានចូលរៀន និងរៀនប្រកបដោយប្រសិទ្ធភាព ។

ខ- ជំរុញសិស្សឱ្យយកចិត្តទុកដាក់ ព្រមទាំងចាប់អារម្មណ៍ដល់សិស្សដទៃ ។

គ- បង្កើនការទទួលខុសត្រូវរបស់កុមារ ។

ឃ- កុមារត្រូវបានលើកទឹកចិត្តច្រើនឱ្យគេបានមករៀន ។

ង- សិស្សមានសេចក្តីក្លាហាន និងមានទំនុកចិត្តក្នុងការរៀនសូត្រ ។

ច- សិស្សមានចិត្តចង់ទៅសាលារៀន ។

ឆ- សិស្សមានចិត្តចង់រៀន ។

ជ- ជួយកាត់បន្ថយអវត្តមាន និងបោះបង់ ។

ឈ- បង្កើនសាមគ្គីភាពរវាង កុមារ និងកុមារ ។

ញ- ការរើសអើងត្រូវបានកាត់បន្ថយ ។

- អ្នកសម្របសម្រួលបិទបង្ហាញចម្លើយរបស់សិក្ខាកាម រួចពិភាក្សាលើចម្លើយទាំងនោះ ។ប្រសិនបើគំនិតយោបល់របស់សិក្ខាកាមមិនបានបង្ហាញជូនដូចចម្លើយខាងលើទេ អ្នកសម្របសម្រួលអាចបញ្ជាក់ចម្លើយជូនសិក្ខាកាម ។
- អ្នកសម្របសម្រួលបញ្ជាក់បន្ថែម មុនបញ្ចប់ការប្រជុំនេះសូមឱ្យបុគ្គលិកតាមសាលាទាំងអស់ ធ្វើយ៉ាងណា ដើម្បីឱ្យសកម្មភាពកុមារជួយកុមារដំណើរការទៅ ប្រកបដោយជោគជ័យ ។

# ឧបសម្ព័ន្ធ ក
# មេរៀនសម្រាប់ជួយកុមារឱ្យចេះអាន និងចេះសរសេរ

**I សេចក្តីផ្តើម :**

មេរៀននេះអាចជួយគ្រូថ្នាក់ទី៥ និងថ្នាក់ទី៦ ដើម្បីបង្រៀនសិស្សរបស់គេ ។បន្ទាប់ពីសិស្សថ្នាក់ទី៥ និងថ្នាក់ទី៦ បានយល់ពីមេរៀននេះ ពួកគេអាចជួយបង្រៀនកុមារនៅថ្នាក់ទី១ និងថ្នាក់ទី២ ឱ្យចេះអាន និងចេះសរសេរ ។

**II គោលបំណង :**

- សិស្សថ្នាក់ទី៥ និងថ្នាក់ទី៦ កំណត់បានសកម្មភាពជួយកុមារ ថ្នាក់ទី១ ឬទី២ឱ្យចេះអាន និងចេះសរសេរ ។

**III រយៈពេល :**

មេរៀននេះចំណាយពេល ៣ ម៉ោង សម្រាប់បង្រៀនសិស្សថ្នាក់ទី៥ និង ថ្នាក់ទី៦ ។

**IV សម្ភារ :**

- ក្រដាសរ៉ាម A ៤. ហ្វឺត . ក្តារខៀន . ដីស

**V លំនាំបង្រៀន :**

- គ្រូត្រូវពន្យល់ប្រាប់សិស្សថា មានសិស្សថ្នាក់ទី១ និងថ្នាក់ទី២ជាច្រើនដែលមានបញ្ហាក្នុងការសរសេរ និងអាន ភាសាខ្មែរ ។ មុខវិជ្ជាភាសាខ្មែរ ជាមុខវិជ្ជាមួយដ៏សំខាន់សម្រាប់រៀនមុខវិជ្ជាផ្សេងៗទៀតដូចជា : គណិតវិទ្យា វិទ្យាសាស្ត្រអនុវត្ត និងសិក្សាសង្គម ។ នៅក្នុងសាលារៀន យើងចង់ផ្តល់ជំនួយបន្ថែមទៀតដល់កុមាររៀន ថ្នាក់ទី១ និងថ្នាក់ទី២ ដែលមានការលំបាកក្នុងការអាន និងការសរសេរ ។ អ្វីដែលយើងចង់រៀបចំធ្វើគឺ :តាម រយៈកុមារជួយកុមារ ។សកម្មភាពនេះគឺមានកុមារពីរនាក់រៀនជាមួយគ្នា កុមារម្នាក់ធ្វើជាអ្នកបង្រៀន ចំណែក កុមារម្នាក់ទៀតធ្វើជាសិស្ស ។ ដូច្នេះកុមារដែលជាគ្រូត្រូវបង្រៀនកុមារម្នាក់ទៀតតាមផែនការ របស់គ្រូប្រចាំ ថ្នាក់ ។ នៅក្នុងសាលារបស់យើងសិស្សថ្នាក់ទី៥ និងថ្នាក់ទី៦ ត្រូវរៀបចំជាគូជាមួយសិស្សនៅថ្នាក់ទី១ និង ថ្នាក់ទី២ ដែលមានការលំបាកក្នុងការអាន និងសរសេរ ។ ក្នុងមេរៀននេះបានបង្ហាញយ៉ាងច្បាស់អំពីរបៀប ជួយ សិស្សនៅថ្នាក់ទី១ និង ថ្នាក់ទី២ ។
- គ្រូរៀបចំសិស្សជាក្រុមតូចៗ រួចធ្វើការសម្តែងតួតាមក្រុមនីមួយៗ ។ សិស្ស ២នាក់ត្រូវជ្រើសរើស ប្រធានបទ មកសម្តែងតួ ដោយទាក់ទងទៅនឹងសកម្មភាពអាន ( សូមមើលប្រអប់លេខ១ ) ។

| ប្រអប់លេខ១ : ការសម្តែងតួសម្រាប់សកម្មភាពអាន |
|---|
| - អានរឿងឱ្យកុមារម្នាក់ទៀតស្តាប់ រួចចង្អុលអក្សរណាមួយនៅក្នុងរឿងដោយសួរថា : តើជាអក្សរអ្វី ? |
| - អានរឿងឱ្យកុមារម្នាក់ទៀតស្តាប់ រួចចង្អុលពាក្យងាយណាមួយនៅក្នុងរឿង រួចសួរសិស្សនោះឱ្យប្រកប ពាក្យ ព្រមទាំងអានឱ្យឮ ។ |
| - ឱ្យកុមារនោះស្វែងរកពាក្យ អក្សរ នោះនៅក្នុងសៀវភៅ ។ |
| - ដោយប្រើរឿងងាយៗ រួចឱ្យកុមារអានរឿងនោះ ។ សូមជួយកុមារនៅពេលដែលគេកំពុងអាន ព្រោះ គេពុំអាចអានបាន ឬពុំយល់ ។ |
| - ច្រៀងចម្រៀងអំពីពាក្យដែលមានក្នុងរឿង ។ |

សិស្សម្នាក់សម្តែងជាសិស្សថ្នាក់ទី១ ឬថ្នាក់ទី២ ហើយសិស្សម្នាក់ទៀតធ្វើជាសិស្សថ្នាក់ទី៥ ឬថ្នាក់ទី៦ ។បន្ទាប់ពីការសម្តែងតួនេះត្រូវត្រូវបញ្ចប់ សិស្សថ្មី២នាក់ទៀតត្រូវសម្តែងតួជាថ្មី ដែលទាក់ទងនឹងសកម្មភាពអានបន្ទាប់ ។

- គ្រូគប្បីសង្ខេបយកគំនិតសំខាន់ៗ នៃការសម្តែងតួនីមួយៗ ហើយត្រូវបញ្ជាក់ឱ្យច្បាស់ថា សិស្សម្នាក់ៗបានយល់ពីការប្រព្រឹត្តិទៅនៃសកម្មភាពនេះ ។ គ្រូអាចសួរសិស្សដោយប្រើសំណួរខាងក្រោម :

- តើប្អូនមានគំនិតយោបល់អ្វីផ្សេងទៀត សម្រាប់សកម្មភាពអាននៅថ្នាក់ទី១ និងថ្នាក់ទី២ ?

- គ្រូត្រូវសរសេរសកម្មភាពអាននីមួយ ៗ ព្រមទាំងគំនិតយោបល់របស់សិស្សនៅក្តារខៀន រួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅ ។
- គ្រូរៀបចំសិស្សជាក្រុមតូចៗ រួចរៀបចំការសម្តែងតួតាមក្រុមនីមួយៗ ។ សិស្ស ២នាក់ ត្រូវជ្រើសរើសការសម្តែងតួដែលទាក់ទងសកម្មភាពសរសេរ （សូមមើលប្រអប់លេខ ២） ។

ប្រអប់លេខ ២ : ការសម្តែងតួសម្រាប់សកម្មភាពសរសេរ

- ឱ្យសិស្សសរសេរពាក្យណាមួយនៅលើក្តារឆ្នួន ឬលើប្រអប់ដីខ្សាច់ ។
- ឱ្យសិស្សសរសេរពាក្យណាមួយនៅលើក្តារឆ្នួន ។
- ចែកអក្សរចល័ត រួចឱ្យសិស្សផ្សំជាពាក្យ ។
- បង្ហាញរូបភាពក្នុងសៀវភៅ រួចសួរសិស្សថា "តើកូនឃើញអ្វីខ្លះ ?" បន្ទាប់មកគេត្រូវប្រើ អក្សរចល័ត ដើម្បីបង្កើតពាក្យនោះ ។ ជាឧទាហរណ៍ : បង្ហាញរូបតា រួចឱ្យសិស្សបង្កើតពាក្យ " តា " ។
- សរសេរពាក្យផ្សេងៗ គ្នា នៅលើក្រដាស រួចឱ្យសិស្សរៀបពាក្យទាំងនោះទៅជាល្បះ ។
- សរសេរអក្សរនៅលើខ្នងរបស់សិស្ស ដោយប្រើម្រាមដៃបន្ទាប់មកឱ្យសិស្សនោះទាយថាតើជាអក្សរអ្វី?
- សរសេរពាក្យ （ពាក្យខុស ឬពាក្យត្រូវ） នៅលើក្តារឆ្នួន រួចឱ្យសិស្សពិនិត្យមើលថា តើពាក្យនេះត្រឹម ត្រូវឬទេ?
-គូររូបភាពជាមួយកុមារដោយទំនាក់ទំនងទៅនឹងពាក្យនៅក្នុងរឿង រួចអនុញ្ញាតឱ្យសរសេរពាក្យនៅក្បែររូបភាព នោះ ។

- សិស្សម្នាក់ដើរតួជាសិស្សថ្នាក់ទី១ ឬថ្នាក់ទី២ ចំណែកសិស្សម្នាក់ទៀតដើរតួជាសិស្សថ្នាក់ទី៥ ឬថ្នាក់ទី៦ ប្រសិនបើសកម្មភាពនេះធ្វើបានត្រឹមត្រូវហើយ សិស្សថ្មី២នាក់ទៀតអាចបន្តការសម្តែងតួដោយមានទំនាក់ទំនងទៅនឹងសកម្មភាពអានបន្ទាប់ ។
- គ្រូគប្បីសង្ខេបគំនិតសំខាន់ៗ នៃការសម្តែងតួនីមួយៗ ហើយត្រូវបញ្ជាក់ឱ្យច្បាស់ថា សិស្សម្នាក់ៗ បានយល់ពីការប្រព្រឹត្តទៅនៃសកម្មភាពនេះ ។ គ្រូសួរសំណួរដូចខាងក្រោម :

~ តើប្អូនមានគំនិតយោបល់អ្វីផ្សេងទៀតសម្រាប់សកម្មភាពសរសេរនៅថ្នាក់ទី១ និង ថ្នាក់ទី២ ?

- គ្រូត្រូវរៀបចំសិស្សជាក្រុមតូចៗ រួចចែកក្រដាសផ្ទាំងធំ ហ្វឺត រួចសួរសិស្សឱ្យឆ្លើយសំណួរដូចខាងក្រោម :

~ តើសកម្មភាពអាន និងសកម្មភាពសរសេរត្រូវធ្វើនៅពេលណា ?

**ចម្លើយ :**

ក- ពេលចេញលេង ។

ខ- មុនពេលរៀន ។

គ- . . . ។ល ។

- តើសកម្មភាពអាន និងសកម្មភាពសរសេរត្រូវធ្វើនៅឯណា ?

**ចម្លើយ :**

ក- បណ្ណាល័យ ។

ខ- បន្ទប់រៀន ( នៅពេលភ្លៀង ឬសាលារៀនដែលគ្មានម្លប់ឈើ ) ។

គ- ក្រៅបន្ទប់រៀន ( ក្រោមដើមឈើ ) ។

ឃ- . . . ។ល ។

- គ្រូពន្យល់ទៀតថា សិស្សថ្នាក់ទី៥ និងថ្នាក់ទី៦ ត្រូវតែស្ម័គ្រចិត្តធ្វើសកម្មភាពកុមារជួយកុមារ ។ ដើម្បីអនុវត្តសកម្មភាពនេះឱ្យបានល្អ សិស្សទាំងអស់ត្រូវចំណាយពេលយ៉ាងហោចណាស់ ១០ ទៅ ១៥ នាទី នៃពេលរៀននៅសាលារបស់ពួកគេ ។ ពួកគេត្រូវតែចេះអត់ធ្មត់ផងដែរ ពីព្រោះការសិក្សារបស់សិស្សនៅថ្នាក់ទី១ និងថ្នាក់ទី២ មានការយឺតយ៉ាវ ជាងនេះទៅទៀតសិស្សថ្នាក់ទី៥ និងថ្នាក់ទី៦ ត្រូវតែមានភាពរីករាយក្នុងការជួយកុមារតូចៗ ។
- គ្រូត្រូវពន្យល់ទៀតថាចំពោះសិស្សណា ដែលមានការចាប់អារម្មណ៍ក្នុងសកម្មភាពកុមារជួយកុមារ គួរតែប្រាប់ឈ្មោះទៅគ្រូរបស់គេ ។ បន្ទាប់ពីរយៈពេល១សប្តាហ៍ សិស្សថ្នាក់ទី៥ និងថ្នាក់ទី៦ នឹងត្រូវបានរៀបចំជាគូជាមួយសិស្សថ្នាក់ទី១ និងសិស្សថ្នាក់ទី២ ។

# ឧបសម្ព័ន្ធ ២
# មេរៀនអំពីការសរសេរសំបុត្ររកមិត្តភក្តិ

## I សេចក្តីផ្តើម :

សំបុត្ររកមិត្តភក្តិគឺជា សំបុត្រដែលប្តូរគ្នាទៅវិញទៅមករវាងសិស្សនៅសាលាមួយទៅសិស្សសាលាមួយទៀត។ ការសរសេរសំបុត្រគឺជាបំណិនមួយដែលអាចបង្កើនចំណេះដឹងតាមរយៈការអនុវត្តជាក់ស្តែង ។ ការសរសេរសំបុត្របានជំរុញឱ្យសិស្សពណ៌នាអំពីខ្លួនគេផ្ទាល់តាមរយៈសំណេរម៉្យាងទៀតគេអាចទទួលបានពីការយល់ដឹងមួយដ៏ប្រសើរចំពោះជីវភាពរស់នៅរបស់សិស្សផ្សេងទៀត ។ សកម្មភាពកុមារជួយកុមារគឺមានឱកាសជួយគ្នាក្នុងការសរសេរសំបុត្រទៅកាន់សិស្សផ្សេងទៀត ដែលរៀននៅសាលាខុសគ្នា ។

## II គោលបំណង :

- សិស្សថ្នាក់ទី៦ កំណត់បានពីរបៀបសរសេរសំបុត្ររកមិត្តភក្តិជាមួយមិត្តរួមថ្នាក់របស់ពួកគេ ។

## III រយៈពេល :

មេរៀននេះចំណាយពេលកន្លះថ្ងៃ សម្រាប់បង្រៀនសិស្សថ្នាក់ទី៦ ។

## IV សម្ភារ :

- ក្រដាសរ៉ាម A 4
- ក្តារខៀន
- ដីស
- គូល័រទៀន
- ស្រោមសំបុត្រ ( ស្រោមសំបុត្រ១ សម្រាប់សិស្ស២ នាក់ )

## V លំនាំបង្រៀន

- គ្រូត្រូវពន្យល់ថាសិស្សទាំងអស់ត្រូវសរសេរសំបុត្រមួយរកមិត្តភក្តិ ។ សំបុត្ររកមិត្តភក្តិត្រូវបានសរសេរដោយសិស្ស ២នាក់ ដែលត្រូវរៀននៅថ្នាក់ទី៦ បន្ទាប់មកគេត្រូវបញ្ជូនសំបុត្រនេះ ទៅសិស្សថ្នាក់ទី៦ ណាមួយដែលរៀននៅសាលាផ្សេងទៀត ។ គ្រូដែលបង្រៀននៅសាលាផ្សេងទៀត ត្រូវចែកចាយសំបុត្រទាំងនេះទៅឱ្យសិស្សអាន ក្រោយពីបានអានរួចត្រូវសរសេរសំបុត្រឆ្លើយតបទៅគេវិញ ។ ដំណើរការនេះចេះតែបន្តរហូតរយៈពេល១ឆ្នាំ ។ ហេតុនេះយើងពិតជាអាចរកមិត្តភក្តិបានតាមរយៈសំបុត្រ ។ គ្រូរៀបចំសិស្សជាក្រុមតូចៗ រួចចែកក្រដាសផ្ទាំងធំ ហ្វឺត ព្រមទាំងសរសេរសំណួរឱ្យសិស្សពិភាក្សាដូចខាងក្រោម :

- តើប្អូនគិតថា មានព័ត៌មានអ្វីខ្លះដែលសំខាន់ ហើយគួរឱ្យចាប់អារម្មណ៍ក្នុងការសរសេរសំបុត្ររកមិត្តភក្តិ ?

**ចម្លើយ :**

  - ឈ្មោះរបស់យើង ។
  - យើងរស់នៅឯណា ?
  - ឈ្មោះសាលារៀន ។
  - កន្លែងដែលសរសេរសំបុត្រ ។
  - ឈ្មោះគ្រូ ។

- មុខរបរឪពុកម្តាយ ។
- ពន្យល់ពីរបៀបដែលយើងកំពុងធ្វើដូចជា :

សកម្មភាពដែលធ្វើបន្ទាប់ពីរៀន ( ស្រែពិសោធ.បំណិនជីវិត. ខ្ចីសៀវភៅពីបណ្ណាល័យ.លេងបាល់ទាត់ .បាល់ទះ លេងល្បែងប្រពៃណី. ការងារប្រចាំថ្ងៃក្នុងការជួយឪពុក ម្តាយ ) អ្វីៗ ដែលចាប់អារម្មណ៍ ឬអស់សំណើច ដែលបានកើតឡើង ។

- គ្រូត្រូវបិទចម្លើយរបស់សិស្សរួចពិភាក្សាលើចម្លើយទាំងនោះ ។ ប្រសិនបើចម្លើយរបស់សិស្សពុំបានបង្ហាញដូច ចម្លើយខាងលើទេ គ្រូអាចបញ្ជាក់ចម្លើយខាងលើឡើងវិញនៅលើក្តារខៀន ។ បន្ទាប់មកសិស្សទាំងអស់ត្រូវ កត់ត្រាចម្លើយទាំងនោះដាក់ក្នុងសៀវភៅរបស់គេ ។

- តើមានសំណួរអ្វីខ្លះ ដែលយើងអាចសួរទៅមិត្តរបស់យើង នៅសាលារៀនផ្សេងទៀត ?

<u>**ចម្លើយ :**</u>

- តើសុខភាពរបស់មិត្តយ៉ាងដូចម្តេចដែរ ?
- តើមិត្តមានបងប្អូនប៉ុន្មាននាក់ ?
- តើសាលារបស់មិត្តនៅក្នុងទីក្រុង ឬ ជនបទ ?
- តើមិត្តទៅសាលារៀនដោយសារអ្វី ?

- គ្រូពន្យល់ថា នៅពេលដែលយើងសរសេរសំបុត្រយើងគួរតែឆ្លើយសំណួរពីអ្វីដែលមិត្តភក្តិរបស់យើងបានសួរនៅ ក្នុងសំបុត្រ ។ ហេតុដូច្នេះហើយយើងគួរតែអានលិខិតរបស់គេឡើងវិញម្តងទៀត មុនពេលសរសេរសំបុត្រថ្មី ។

- តើយើងគួរតែបញ្ចប់សេចក្តីសំបុត្រយ៉ាងដូចម្តេច ?

<u>**ចម្លើយ :**</u>

- ប្រើពាក្យលា ។
- ជូនពរ ។
- ឱ្យសរសេរសំបុត្រត្រឡប់មកវិញ ។
- ចុះហត្ថលេខា ។
- គូររូបភាពនៅក្បែរម្ខាងនៃសំបុត្រ ឬ ដាក់រូបភាពផ្សេងៗ ក្នុងស្រោមសំបុត្រ. . . . ។ល។

- គ្រូបន្តពន្យល់ទៀតថា ក្នុងការសរសេរសំបុត្ររកមិត្តភក្តិ ត្រូវសរសេរដោយមានគ្នា ២នាក់ បន្ទាប់មកគ្រូត្រូវ អានបញ្ជីឈ្មោះសិស្សដែលបានកំណត់ តើអ្នកណាជាគូជាមួយអ្នកណា? ។ សិស្ស ២៧ នាក់ ចាប់ផ្តើមសរសេរ សំបុត្រ ហើយគ្រូជាអ្នកផ្តល់ជំនួយ ប្រសិនបើចាំបាច់ ។

## ឧបសម្ព័ន្ធ គ

## មេរៀនសម្រាប់ជួយកុមារនៅពេលរៀនក្នុងក្លឹបសិក្សាលើមុខវិជ្ជា ភាសាខ្មែរ និង គណិតវិទ្យា

### I. សេចក្តីផ្តើម

មេរៀននេះអាចជួយគ្រូថ្នាក់ទី៤ ទី៥ និងថ្នាក់ទី៦ ដើម្បីបង្រៀនសិស្សរបស់គេពីរបៀបរៀននៅក្នុងក្លឹបសិក្សាឱ្យបានទទួលលទ្ធផលល្អ ។ បន្ទាប់ពីសិស្សថ្នាក់ទី៤ ទី៥ និងថ្នាក់ទី៦ យល់បានពីមេរៀននេះ ក្លឹបសិក្សារបស់គេទទួលបានជោគជ័យ និងប្រកបដោយគុណភាព។

### II. គោលបំណង

- សិស្សថ្នាក់ទី៤ ទី ៥ និងថ្នាក់ទី៦ ត្រូវកំណត់បានពីរបៀបគ្រប់គ្រងគ្នាឯងនៅក្នុងក្លឹបសិក្សា ។
- សិស្សថ្នាក់ទី៤ ទី ៥ និងថ្នាក់ទី៦ កំណត់បានពីរបៀបរៀនក្នុងក្លឹបសិក្សា ។

### III. រយៈពេល

មេរៀននេះ ចំណាយពេល ២ម៉ោង សម្រាប់បង្រៀនសិស្ស ថ្នាក់ទី៤ ទី៥ និងថ្នាក់ទី៦ ។

### IV. សម្ភារៈ

- ក្រដាសវ៉ាម អា ៤ .ហ្វឺត . ក្តារខៀន . ដីស .សៀវភៅពុម្ពសិស្សតាមកម្រិតថ្នាក់( ភាសាខ្មែរ.គណិតវិទ្យា

### V. លំនាំការបង្រៀន

- គ្រូត្រូវពន្យល់ថា រាល់មេរៀនដែលសិស្សថ្នាក់ទី ៤ ទី៥ និងថ្នាក់ទី៦ ទទួលបានចំណេះដឹងពីគ្រូកន្លងមកនៅសាលារៀនដូចជា មុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យា សិស្សមួយចំនួនក៏មិនប្រាកដច្បាស់ថា ចាំច្បាស់បានរាល់ចំណុចនោះឡើយ ។ ដូច្នេះដើម្បីបំពេញរាល់ចំណុចដែលខ្វះខាតទាំងនោះបានគឺមានតែសកម្មភាពកុមារជួយកុមារ។ សកម្មភាពកុមារជួយកុមារត្រូវរៀបចំដោយសិស្សមួយក្រុម អង្គុយរៀនជាមួយគ្នា ជួយបង្ហាញនូវអ្វីដែលគេមិនយល់ តាមរយៈការបញ្ចេញមតិយោបល់ទៅវិញទៅមកនៅក្នុងក្រុមរបស់គេ ។ ក្លឹបសិក្សានេះមានតំណាងសិស្សម្នាក់ក្នុងមួយថ្ងៃ ធ្វើជាអ្នកសម្របសម្រួល ប៉ុន្តែសិស្សនេះមិនមែនជាអ្នកបង្រៀនទេ ។ ក្នុងមេរៀននេះ បានបង្ហាញអំពីរបៀបរៀនក្នុងក្លឹបសិក្សា នៅថ្នាក់ទី៤ ទី៥ និង ថ្នាក់ទី៦ ។
- គ្រូរៀបចំសិស្សជាក្រុម ដោយក្រុមនីមួយៗ ត្រូវមានតំណាងសិស្សម្នាក់ ដើម្បីធ្វើជាអ្នកសម្របសម្រួល ។ ក្រុមទី១ រៀបចំមេរៀនគណិតវិទ្យា និងក្រុមទី២ រៀបចំមេរៀនភាសាខ្មែរ រួចធ្វើការសម្តែងតួ ។

ប្រអប់លេខ ១ : ការសម្តែងតួសម្រាប់សកម្មភាពរៀនក្នុងក្លឹបសិក្សា

- សិស្សជាអ្នកសម្របសម្រួល ឡើងធ្វើការសំណេះសំណាល រួចសួរដល់សិស្សក្នុងក្លឹបទាំងអស់
- តើថ្ងៃនេះមិត្តយើងទាំងអស់មានចម្ងល់លើមេរៀនអ្វីខ្លះ?
- អ្នកសម្របសម្រួលហៅឈ្មោះសិស្សដែលមានចម្ងល់មកក្តារខៀន
- សិស្សម្នាក់ឡើងសរសេរលំហាត់មួយដែលវាមិនយល់នៅក្តារខៀន ។
- ឧទាហរណ៍ $\frac{2}{5}$ $\frac{1}{5}$ $\frac{\square}{\square}$

- អ្នកសម្របសម្រួលហោឈ្មោះសស្សក្នុងក្រុមម្នាក់ (ជាសិស្សបានលើកដៃ) មកក្តារខៀន
 -ដើម្បីជួយដោះស្រាយលើលំហាត់នេះជាជំហានៗៈដោយគ្រាន់តែប្រើសំណួរបំផុសអំពីៈ

១, ឈ្មោះរបស់លំហាត់នេះ ( បូកប្រភាគ នឹង ប្រភាគដែលមានភាគបែងដូចគ្នា )

២, បញ្ហារបស់លំហាត់ ( បំពេញលេខក្នុងប្រអប់តម្រូវតាមលទ្ធផល )

៣, បញ្ញតិ រី វិធានរបស់លំហាត់ (  បូកភាគយកនឹងភាគយក ឯភាគបែងរក្សានៅដដែល )

៤,  ធ្វើប្រមាណវិធីតាមដំណាក់ៗដោយចង្អុលបង្ហាញ (២បូក១ស្មើ៣  ហើយភាគបែង៥ រក្សាទុកនៅដដែល)

ក្នុងជំហាន ( ១ - ២- ៣ ) សិស្សដែលជាអ្នកសម្របសម្រួល ត្រូវសួរសិស្សដទៃទៀត បើសិនជំហានណាមួយមិនទាន់ច្បាស់ ឬបកស្រាយមិនត្រឹមត្រូវ ដោយគ្រាន់តែប្រើសំណួរ តើមានមិត្តណាមានគំនិតយោបល់ខុសពីនេះ (អ្នកសម្របសម្រួលនៅតែប្រើសំណួរនេះដដែលបើសិនចម្លើយនៅតែមិនត្រឹមត្រូវ)។ ក្រោយពីបានដោះស្រាយរួចអ្នកសម្របសម្រួលដាក់លំហាត់មួយទៀតឱ្យទៅសិស្សដែលមានចម្ងល់(លំហាត់ស្រដៀងគ្នា)។

- អ្នកសម្របសម្រួល ឬប្រធានក្រុម ឱ្យសិស្សដែលមានចម្ងល់នេះ ឡើងធ្វើលំហាត់នៅក្តារខៀន ។
- អ្នកសម្របសម្រួលដាក់លំហាត់វិធីបូកប្រភាគដែលភាគបែងដូចគ្នា ពីរ ឬបីលំហាត់ដល់សិស្សក្នុងក្រុមទាំងអស់ បន្ទាប់មកប្រមូលធ្វើកំណែរួម ។
- អ្នកសម្របសម្រួល សួរទៅសិស្សដទៃទៀត តើមានមិត្តណាទៀតមានចម្ងល់លើលំហាត់អ្វីទៀត ?

ក្នុងមេរៀននីមួយៗ ធ្វើរបៀបនេះ រហូតដល់ពេលបញ្ចប់ការសិក្សានៅក្លឹបនេះ ។ គ្រូគប្បីសង្ខេបយកគំនិតសំខាន់ៗនៃការសម្តែងតួ ហើយត្រូវបញ្ជាក់ឱ្យច្បាស់ថា សិស្សទាំងអស់គ្នាបានយល់ពីការប្រព្រឹត្តទៅនៃសកម្មភាពនេះ ។

- គ្រូអាចសួរសិស្សដោយប្រើសំណួរខាងក្រោម :

- តើប្អូនមានគំនិតយោបល់អ្វីផ្សេងទៀត សម្រាប់សកម្មភាពក្លឹបសិក្សានេះ ?

- គ្រូត្រូវសរសេរសកម្មភាពនីមួយៗ ព្រមទាំងគំនិតយោបល់របស់សិស្សនៅក្តារខៀន រួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅ ។
- គ្រូឱ្យក្រុមមួយទៀតធ្វើការសម្តែងតួដែលទាក់ទងមេរៀនភាសាខ្មែរ (សូមមើលប្រអប់លេខ ២)

<u>ប្រអប់លេខ ២</u> : ការសម្តែងតួដែលទាក់ទងនឹងមេរៀន ភាសាខ្មែរ

សិស្សជាអ្នកសម្របសម្រួល ឡើងធ្វើការសំណេះសំណាល រួចសួរដល់សិស្សក្នុងក្លឹបទាំងអស់

- តើថ្ងៃនេះមិត្តយើងទាំងអស់មានចម្ងល់លើមេរៀនអ្វីខ្លះ ?
- អ្នកសម្របសម្រួលហៅឈ្មោះសិស្សដែលមានចម្ងល់មកក្តារខៀន
- សិស្សម្នាក់ឡើងសរសេរពាក្យមួយដែលវាមិនយល់នៅក្តារខៀន ។ ឧទាហរណ៍ : លំហាត់ក្នុងសៀវភៅភាសាខ្មែរថ្នាក់ទី៤ទំព័រ ៥៤: ១-នៅតាមមន្ទីរពេទ្យនានាមានដាំផ្កាផ្សេងៗ ។<u>បុប្ផា</u> ទាំងនោះមានពិណស្រស់បំព្រងក្លិនក្រអូបធ្វើឱ្យអារម្មណ៍អ្នកជម្ងឺបានធូរស្រាល។
- អ្នកសម្របសម្រួលហៅឈ្មោះសិស្សក្នុងក្រុមម្នាក់ (ជាសិស្សបានលើកដៃ) មកក្តារខៀន ដើម្បីបញ្ជាក់លើលំហាត់នេះ ដោយ :

១- លំហាត់នេះគេឱ្យយើងរកពាក្យន័យដូច នឹងពាក្យបុប្ផាដែលមានគំនូសពីក្រោម។

២-ប្រាប់ឈ្មោះមេរៀនរបស់លំហាត់នេះ (ពាក្យន័យដូចនៅក្នុងស-សទំព័រ៥៤)

៣-សូត្រនិយមន័យរបស់លំហាត់ ( ពាក្យន័យដូចគឺជាពាក្យដែលមានន័យដូចគ្នា តែមានសំណេរខុសគ្នា) ដូច្នេះពាក្យន័យដូចនឹងពាក្យបុប្ផាគឺ ផ្កា

៤-អ្នកសម្របសម្រួលដាក់ឧទាហរណ៍មួយទៀតដល់សិស្សមានចម្ងល់

៥-អ្នកសម្របសម្រួលដាក់លំហាត់ពីរ ឬបី ដល់សិស្សក្នុងក្រុម

៦-ប្រមូលកិច្ចការធ្វើកំណែរួម

- គ្រូត្រូវរៀបចំសិស្សជាក្រុមតូច រួចចែកក្រដាសផ្ទាំងធំ ហ្វឺត ហើយសួរសិស្សឱ្យឆ្លើយសំណួរដូចខាងក្រោម :

- តើសកម្មភាពក្លឹបសិក្សានេះអាចធ្វើនៅឯណាខ្លះ ?

ចម្លើយ

ក- នៅតាមផ្ទះ ។

ខ- ក្រោមដើមឈើ ។

- តើសកម្មភាពក្លឹបសិក្សានេះអាចធ្វើបាននៅពេលណាខ្លះ ?

ចម្លើយ

ក-ខុសពីពេលរៀននៅសាលារដ្ឋ ។

ខ-ពេលទំនេរ ។

- គ្រូបិទបង្ហាញចម្លើយរបស់សិស្សនៅលើជញ្ជាំងរួចធ្វើការពិភាក្សាលើចម្លើយទាំងនោះ ។ប្រសិនបើគំនិតយោបល់របស់សិស្សពុំបានបង្ហាញដូចចម្លើយខាងលើទេ គ្រូត្រូវបញ្ជាក់ចំណុចទាំងនោះឱ្យសិស្ស ។
- គ្រូត្រូវពន្យល់បន្ថែមថាសិស្សថ្នាក់ទី៤ ទី៥ និងថ្នាក់ទី៦ ត្រូវតែនាំគ្នារៀបចំក្លឹបសិក្សានេះដើម្បីជាប្រយោជន៍ក្នុងការជួយមិត្តភក្តិយើងផង ពិសេសខ្លួនយើងផងដែរ ។ យើងត្រូវធ្វើយ៉ាងណា ជួយបង្កលក្ខណៈឱ្យបានច្រើនដល់មិត្តភក្តិណា ដែលជួបបញ្ហាដូចខាងក្រោម :

  ១- សិស្សមានអវត្តមានច្រើននៅសាលារៀន ។

  ២- សិស្សក្រីក្រ ។

  ៣- សិស្សមានទីលំនៅឆ្ងាយពីសាលារៀន ។

  ៤- សិស្សខ្សោយលើមុខវិជ្ជា ភាសាខ្មែរ និង គណិតវិទ្យា ។

  ៥- សិស្សមានសេចក្តីប្រថុយក្នុងការបោះបង់ ។

  ៦- សិស្សពិការ ។

# ឧបសម្ព័ន្ធ ឃ
# មេរៀននេះសម្រាប់ជួយកុមារពិការជើង

**I. សេចក្ដីផ្ដើម :**

មេរៀននេះអាចជួយគ្រូគ្រប់ថ្នាក់ ដើម្បីបង្រៀនសិស្សរបស់គេ ពីរបៀបជួយដល់សិស្សពិការជើងឱ្យបានចូលរៀននិងរៀនប្រកបដោយក្ដីសប្បាយរីករាយ ។ បន្ទាប់ពីសិស្សគ្រប់ថ្នាក់បានយល់ពីមេរៀននេះ ពួកគេអាចជួយដល់សិស្សពិការជើងបានគ្រប់ពេល ។

**II. គោលបំណង :**

-សិស្សគ្រប់ថ្នាក់កំណត់បានពីភាពលំបាករបស់កុមារពិការនៅពេលទៅសាលារៀន និងពេលរៀន ។

-សិស្សគ្រប់ថ្នាក់កំណត់យុទ្ធវិធីផ្សេងៗ ដើម្បីជួយកុមារពិការជើងឱ្យមករៀន និងរៀនដោយក្ដីសប្បាយរីករាយ ។

**III. រយៈពេល :**

មេរៀននេះចំណាយពេល ១ ម៉ោង សម្រាប់បង្រៀនសិស្សដែលត្រូវជួយសិស្សពិការជើង ។

**IV. សម្ភារៈ**

- ក្រដាសរ៉ាម A4
- ផ្ទាំងសំណួរ
- ហ្វឺត
- ក្ដារខៀន
- ដីស
- ក្រមា
- បន្ទះឈើ

**V**. លំនាំបង្រៀន :

- គ្រូត្រូវពន្យល់ប្រាប់សិស្សថា មានសិស្សពិការជើងមួយចំនួនដែលពុំទាន់បានចូលរៀន និងមួយចំនួនទៀត បានចូលរៀនហើយ តែពួកគេកំពុងរង់ចាំជំនួយពីយើងទាំងអស់គ្នា ដើម្បីជួយពួកគេឱ្យបានចូលរៀន និងរៀនប្រកបដោយក្ដីសប្បាយរីករាយ ។
- គ្រូរៀបចំសិស្សជាក្រុម ( ចំនួនក្រុមជាក់ស្ដែងទៅតាមចំនួនសិស្ស ) ចែកក្រដាសផ្ទាំងធំ ហ្វឺត រួចដាក់សំណួរឱ្យសិស្សពិភាក្សាដូចខាងក្រោម :

  ១- តើប្អូនបានស្គាល់កុមារណាខ្លះនៅក្នុងភូមិ ឬនៅក្នុងសាលារៀនដែលមិនអាចដើររត់ ឬធ្វើសកម្មភាពផ្សេងៗដែរ ឬ ទេ ?

  ២- ហេតុអ្វីបានជាកុមារទាំងនោះមិនអាចធ្វើអ្វីដូចដែលប្អូនអាចធ្វើបាន ?

  ៣- តើភាពពិការនេះវាជាកំហុសរបស់កុមារពិការនោះដែរ ឬទេ ? ព្រោះអ្វី ?

៤- តើកន្លងមកប្អូនបានធ្វើអ្វីខ្លះដល់កុមារពិការ ? តើអំពើទាំងនោះជាអំពើល្អ ឬជាអំពើអាក្រក់ ?

៥- តើកន្លងមកប្អូនចូលចិត្តឱ្យកុមារពិការនេះលេងល្បែងជាមួយប្អូនដែរ ឬទេ ? ព្រោះអ្វី ?

៦- តើប្អូនមានអារម្មណ៍យ៉ាងដូចម្ដេច បើសិនប្អូនមានបញ្ហាស្រដៀងគ្នាដូចកុមារពិការនោះ ?

៧- បើសិនប្អូនមានបញ្ហាដូចនេះ តើប្អូនចង់ឱ្យកុមារផ្សេងទៀតប្រព្រឹត្តយ៉ាងដូចម្ដេចចំពោះប្អូន ?

៨- តើប្អូនពេញចិត្តឱ្យពួកគេធ្វើការសើចចំអកដាក់ប្អូន ឬទេ ? ព្រោះអ្វី ?

៩- តើប្អូនពេញចិត្តឱ្យពួកគេក្លាយជាមិត្តភក្ដិរបស់ប្អូន ឬទេ ? ព្រោះអ្វី ?

- គ្រូឱ្យសិស្សបិទចម្លើយរបស់សិស្សនៅលើជញ្ជាំង រួចពិភាក្សាលើចម្លើយទាំងនោះ ។ ប្រសិនបើគំនិតយោបល់របស់សិស្ស ពុំបានបង្ហាញច្បាស់លាស់ទេ លោកគ្រូត្រូវបញ្ជាក់ចំណុចទាំងនោះបន្ថែម ។
- គ្រូរៀបចំសិស្សតាមក្រុម រួចចែកក្រដាសផ្ទាំងធំ ហ្វឺត រួច ដាក់សំណួរឱ្យសិស្សពិភាក្សាដូចខាងក្រោម :

- តើប្អូនត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីជួយដល់កុមារពិការជើងឱ្យបានចូលរៀន និងរៀនប្រកបដោយក្ដីសប្បាយរីករាយ ?

<u>**ចម្លើយ**</u>

ក-ជួយជំរុញកុមារពិការជើងឱ្យបានចុះឈ្មោះចូលរៀន ។

ខ-ជួយឌុបកង់កុមារពិការជើងទៅ និងមកសាលារៀន ។

គ-មិនត្រូវសើចចំអក ឬប្រើពាក្យមិនសមរម្យដល់កុមារពិការ ។

ឃ-ជួយដឹកដៃកុមារពិការ ។

ង-ជួយបង្កើតល្បែងដើម្បីលេងជាមួយ ។

ច-ជួយរុញរទេះបើសិនសិស្សពិការនោះមានរទេះ ។

ឆ-ជួយធ្វើជំរេល (ប្លង់ទេ) នៅមុខថ្នាក់ ។

- គ្រូឱ្យសិស្សបិទចម្លើយនៅលើជញ្ជាំង រួចធ្វើការពិភាក្សាលើចម្លើយទាំងនោះ ។ ប្រសិនបើគំនិតយោបល់របស់សិស្ស ពុំបានបង្ហាញដូចចម្លើយខាងលើទេ អ្នកសម្របសម្រួលត្រូវបញ្ជាក់ចំណុចទាំងនោះបន្ថែម ។
- គ្រូរៀបចំសិស្សជាក្រុមតូចៗ រួចធ្វើការសម្ដែងតួតាមក្រុមនីមួយៗ (ជ្រើសរើសសកម្មភាពដែលបានកំណត់ខាងលើ) ដោយឱ្យសិស្សក្នុងក្រុមនីមួយៗ មានមួយនាក់ ឬពីរនាក់ធ្វើជាសិស្សពិការជើង ហើយសិស្សដ៏ទៃទៀតធ្វើជាអ្នកជួយពិសេស ។
- គ្រូរៀបចំសិស្ស ៦ ទៅ៧ នាក់ ដើម្បីធ្វើការសម្ដែងតួ ទាក់ទងនឹងសកម្មភាពបបួលសិស្សពិការឱ្យចូលរៀន សិស្ស ២ នាក់ សម្ដែងតួជាឪពុក ម្ដាយសិស្សពិការ និង សិស្សដទៃទៀតជាមិត្តរបស់កុមារពិការ ។

  ក្រុមទី១ : ប្រធានបទសម្ដែងតួ ដោយទាក់ទង នឹង សកម្មភាព បបួលកុមារពិការមកចុះឈ្មោះចូលរៀន

( ប្រអប់លេខ១)

ប្រអប់លេខ ១ : ការសម្តែងតួ ការជួយជំរុញកុមារពិការឱ្យបានចូលរៀន
- ការគួរសមនៅពេលជួបម្តាយឪពុកក្មេងពិការ
- ប្រាប់ពីគោលបំណងដែលមកទីនេះ ( ចង់បបួលកុមារពិការឱ្យបានចូលរៀន )
- បង្ហាញប្រាប់ពីសកម្មភាពជួយកុមារពិការខ្លះៗ ( ពេលរៀបចំធ្វើដំណើរមកសាលារៀន ពេលកំពុងរៀនពេលចេញលេង និងពេលត្រឡប់មកផ្ទះវិញ )
- សម្តែងនូវភាពរីករាយនៅពេលដែលឪពុក ម្តាយកុមារពិការនោះយល់ព្រមឱ្យកូនគាត់បានទៅរៀន ។
- ការគួរសមនៅពេលលាឪពុកម្តាយ កុមារពិការ ។

បន្ទាប់ពីការសម្តែងតួនេះត្រូវបញ្ចប់ គ្រូគប្បីសង្ខេបយកគំនិតសំខាន់ៗ នៃការសម្តែងតួ ហើយត្រូវបញ្ជាក់ឱ្យច្បាស់ថា:សិស្សទាំងអស់គ្នាបានយល់ពីការប្រព្រឹត្តទៅនៃសកម្មភាពនេះ ។ គ្រូអាចសួរសិស្សដោយប្រើសំណួរខាងក្រោម :

- តើប្អូនមានគំនិតយោបល់អ្វីផ្សេងទៀត សម្រាប់សកម្មភាពនេះ ?
- គ្រូត្រូវសរសេរសកម្មភាពនីមួយៗ ព្រមទាំងគំនិតយោបល់របស់សិស្សនៅក្តារខៀន រួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅ ។

ប្រធានបទមកសម្តែងតួ ដោយទាក់ទង នឹងសកម្មភាពបង្កើតល្បែងលេងជាមួយសិស្សពិការជើង ( ប្រអប់លេខ២)

ប្រអប់លេខ ២ : ការសម្តែងតួ បង្កើតល្បែងលេងជាមួយសិស្សពិការ
-សិស្សម្នាក់ដើរតួជាសិស្សពិការ ( សិស្សពីរនាក់ជាអ្នករៀបចំ ជើងសិប្ប)
-សិស្ស៤ ទៅ ៥ នាក់ ដើរតួជាអ្នកលេងល្បែងជាមួយ
-សិស្ស៤ ទៅ ៥ នាក់ ដើរតួជាអ្នកឈរមើលដោយប្រើពាក្យសើចចំអក

បន្ទាប់ពីការសម្តែងតួនេះត្រូវបញ្ចប់ គ្រូគប្បីសង្ខេបយកគំនិតសំខាន់ៗ នៃការសម្តែងតួ ហើយត្រូវបញ្ជាក់ឱ្យច្បាស់ថា: សិស្សទាំងអស់គ្នាបានយល់ពីការប្រព្រឹត្តទៅនៃសកម្មភាពនេះ ។ គ្រូអាចសួរសិស្សដោយប្រើសំណួរខាងក្រោម :

- តើប្អូនមានគំនិតយោបល់អ្វីផ្សេងទៀត សម្រាប់សកម្មភាពនេះ? គ្រូត្រូវសរសេរសកម្មភាពនីមួយៗ ព្រមទាំងគំនិតយោបល់របស់សិស្សនៅក្តារខៀន រួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅ ។

# ឧបសម្ព័ន្ធ ១
# មេរៀននេះសម្រាប់ជួយកុមារមានបញ្ហាភ្នែក

## I. សេចក្តីផ្តើម :

មេរៀននេះ អាចជួយគ្រូគ្រប់ថ្នាក់ ដើម្បីបង្រៀនសិស្សរបស់គេពីរបៀបជួយដល់សិស្សមានបញ្ហាភ្នែក ឱ្យបានរៀនប្រកបដោយក្តីសប្បាយរីករាយ ។ បន្ទាប់ពីសិស្សគ្រប់ថ្នាក់ បានយល់ពីមេរៀននេះ ពួកគេអាចជួយដល់សិស្សមានបញ្ហាភ្នែកបានគ្រប់ពេលសិក្សា ។

## II. គោលបំណង :

-សិស្សគ្រប់ថ្នាក់កំណត់បានពីភាពលំបាករបស់សិស្សមានបញ្ហាភ្នែក ក្នុងពេលរៀន។

-សិស្សគ្រប់ថ្នាក់ កំណត់យុទ្ធវិធីផ្សេងៗដើម្បីជួយកុមារមានបញ្ហាភ្នែក ឱ្យរៀនបានគ្រប់ម៉ោងសិក្សា។

## III. រយៈពេល :

មេរៀននេះចំណាយពេល មួយម៉ោង សម្រាប់បង្រៀនសិស្សដែលត្រូវជួយសិស្សមានបញ្ហាភ្នែក។

## IV. សម្ភារៈ

- ក្រដាសរ៉ាម A4
- ហ្វឺត
- ក្តារខៀន
- ដីស

## V. លំនាំបង្រៀន :

- គ្រូត្រូវពន្យល់ប្រាប់សិស្សថា សិស្សដែលមានបញ្ហាភ្នែកគឺជួបបញ្ហាខ្លាំងក្នុងការសិក្សា បើសិនភ្នែកពួកគេពុំអាចមើលអក្សរនៅលើក្តារខៀនឃើញ ឬឃើញព្រិលៗ។ បញ្ហាខាងលើនេះជាឧបសគ្គដ៏ធ្ងន់ធ្ងរសម្រាប់ពួកគេ។ ដូច្នេះដើម្បីជួយពួកគេឱ្យបានរៀន ប្រកបដោយក្តីសប្បាយរីករាយនិងទទួលបានលទ្ធផលល្អ យើងទាំងអស់គ្នាត្រូវចូលរួមក្នុងសកម្មភាពនេះ ។ សាលារៀនត្រូវរៀបចំសកម្មភាពកុមារជួយកុមារ ដើម្បីជួយគាំទ្រសិស្សមានបញ្ហាភ្នែក ។
- គ្រូរៀបចំសិស្សតាមក្រុម (ចំនួនក្រុមជាក់ស្តែងទៅតាមចំនួនសិស្ស) រួចចែកក្រដាសផ្ទាំងធំ ហ្វឺតរួចដាក់សំណួរឱ្យសិស្សពិភាក្សាដូចខាងក្រោម :

- តើប្អូនត្រូវធ្វើដូចម្តេចខ្លះក្នុងការជួយសិស្សមានបញ្ហាភ្នែក ដើម្បីឱ្យពួកគេអាចរៀនបានដូចសិស្សដទៃទៀត ?
  ចម្លើយ

  ក- រៀបចំឱ្យអង្គុយតុមុខ ។

ខ- អង្គុយក្បែរទ្វារ ឬ បង្អួច ។

គ- អក្សរ ឬ លេខត្រូវសរសេរឱ្យធំៗនៅក្តារខៀន ។

ឃ-ឱ្យចម្លងមេរៀននៅពេលសិស្សនោះពិបាកសម្លឹងមើលអក្សរនៅក្តារខៀន ។

ង- ជួយអំណានអក្សរនៅក្តារខៀន។

ច-ជួយផ្តល់មេរៀនឱ្យចម្លងនៅផ្ទះនៅពេលសិស្សនោះចម្លងមេរៀនពីគ្រូពុំទាន់ចប់ ។

ឆ-មិនត្រូវសើច ចំអករាល់ការខុសឆ្គងផ្សេងៗ ។

ជ-ជួយជំរុញ ឱ្យពួកគេបានចូលរួមក្នុងសកម្មភាពក្រុមឱ្យបានច្រើន ។

- គ្រូឱ្យសិស្សបិទចម្លើយនៅលើជញ្ជាំង រួចធ្វើការពិភាក្សាលើចម្លើយទាំងនោះ ។ ប្រសិនបើគំនិតយោបល់របស់សិស្សពុំបានបង្ហាញដូចចម្លើយខាងលើទេ អ្នកសម្របសម្រួលត្រូវបញ្ជាក់ចំណុចទាំងនោះឱ្យ សិស្ស។
- គ្រូបញ្ជាក់បន្ថែមថា បើយើងអាចធ្វើបាននូវអ្វីដែលយើងបានកំណត់នេះ សិស្សដែលមានបញ្ហាភ្នែកប្រាកដជាមានអារម្មណ៍ល្អក្នុងការសិក្សា និងរៀនប្រកបដោយជោគជ័យ ។ គ្រូរៀបចំសិស្សជា២ក្រុម ក្រុមទី១សម្តែងតួក្នុងសកម្មភាព (ជួយសិស្សមានបញ្ហាភ្នែក ត្រង់ចំណុច ឃ និង ង) ក្រុមទី២សម្តែងតួ (ជួយសិស្សមានបញ្ហាភ្នែក ត្រង់ចំណុច គ )
- ការសម្តែងតួសម្រាប់សកម្មភាព ត្រង់ចំណុច គ ឃ និង ង (សូមមើលប្រអប់លេខ១ )

| |
|---|
| ប្រអប់លេខ ១ ការសម្តែងតួ សកម្មភាពជួយសិស្សមានបញ្ហាភ្នែក<br>-គ្រូចម្លងអត្ថបទ នៅក្តារខៀន មួយជួរ ឬ ពីរជួរ<br>-សិស្សជាអ្នកជួយពិសេសបង្កលក្ខណៈឱ្យសិស្សមានបញ្ហាភ្នែកងាយស្រួលក្នុងការចម្លង<br>-សិស្សមានបញ្ហាភ្នែកចម្លងតាមពីសៀវភៅ<br>-ជួយអានអក្សរនៅក្តារខៀនដើម្បីឱ្យសិស្សមានបញ្ហាភ្នែកចម្លងចូលសៀវភៅរបស់គេ<br>-គ្រូហៅសិស្ស ម្នាក់ឡើងសរសេរពាក្យ នៅក្តារខៀន<br>-សិស្សឡើងសរសេរពាក្យនោះ (សរសេរអក្សរធំ ៗ )<br>-គ្រូធ្វើរបៀបនេះពីរ ទៅ ៣ដង |

- សិស្ស២នាក់សម្តែងតួជាអ្នកជួយពិសេស សិស្សម្នាក់ទៀតសម្តែងតួជាសិស្សមានបញ្ហាភ្នែក ។ បន្ទាប់ពីការសម្តែងតួនេះត្រូវបញ្ចប់គ្រូគប្បីសង្ខេបយកគំនិតសំខាន់ៗ នៃការសម្តែងតួ ហើយត្រូវបញ្ជាក់ឱ្យច្បាស់ថា សិស្សទាំងអស់គ្នា បានយល់ពីការប្រព្រឹត្តទៅនៃសកម្មភាពនេះ ។ គ្រូអាចសួរសិស្សដោយ ប្រើសំណួរ ខាងក្រោម :

- តើប្អូនមានគំនិតយោបល់អ្វីផ្សេងទៀត សម្រាប់សកម្មភាពនេះ ?

- គ្រូត្រូវសរសេរសកម្មភាពនីមួយៗ ព្រមទាំងគំនិតយោបល់របស់សិស្សនៅក្តារខៀន រួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅ ។

## ឧបសម្ព័ន្ធ ច

## មេរៀននេះសម្រាប់ជួយកុមារមានបញ្ហាត្រចៀក

**I. សេចក្តីផ្តើម :**

មេរៀននេះអាចជួយគ្រូគ្រប់ថ្នាក់ ដើម្បីបង្រៀនសិស្សរបស់គេពីរបៀបជួយដល់សិស្សមានបញ្ហាត្រចៀក ឱ្យរៀនប្រកបដោយក្តីសប្បាយរីករាយ និងប្រកបដោយគុណភាព ។ បន្ទាប់ពីសិស្សគ្រប់ថ្នាក់ បានយល់ពីមេរៀននេះ ពួកគេអាចជួយដល់សិស្សមានបញ្ហាត្រចៀកបានគ្រប់ពេលសិក្សា ។

**II. គោលបំណង :**

-សិស្សគ្រប់ថ្នាក់កំណត់បានពីភាពលំបាករបស់សិស្ស មានបញ្ហាត្រចៀកនៅពេលរៀន ។

-សិស្សគ្រប់ថ្នាក់ កំណត់យុទ្ធវិធីផ្សេងៗដើម្បីជួយកុមារមានបញ្ហាត្រចៀក ឱ្យបានគ្រប់ម៉ោងសិក្សា។

**III. រយៈពេល :**

មេរៀននេះចំណាយពេល មួយម៉ោង សម្រាប់បង្រៀនសិស្សដែលត្រូវជួយសិស្សមានបញ្ហាត្រចៀក។

**IV. សម្ភារៈ**

- ក្រដាសរ៉ាម A4
- ហ្វឺត
- ក្តារខៀន
- ដីស

**V. លំនាំបង្រៀន :**

- គ្រូត្រូវពន្យល់ប្រាប់សិស្សថា សិស្សដែលមានបញ្ហាត្រចៀក គឺជួបបញ្ហាខ្លាំងក្នុងការសិក្សា បើសិនពួកគេពុំអាចស្តាប់បាននូវពាក្យពេចន៍ ឬខ្លឹមសារដែលគ្រូបានផ្តល់ឱ្យតាមរយៈការពន្យល់ និងការណែនាំពីគ្រូ។ បញ្ហាខាងលើនេះជាឧបសគ្គដ៏ធ្ងន់ធ្ងរសម្រាប់ពួកគេ ដូច្នេះដើម្បីជួយពួកគេឱ្យបានរៀនប្រកបដោយក្តីសប្បាយរីករាយ និងទទួលបានលទ្ធផលល្អ សាលាត្រូវបានរៀបចំសកម្មភាពកុមារជួយកុមារដើម្បីជួយគាំទ្រសិស្សមានបញ្ហាត្រចៀក
- គ្រូរៀបចំសិស្សតាមក្រុម (ចំនួនក្រុមជាក់ស្តែងទៅតាមចំនួនសិស្ស) ចែក ក្រដាសផ្ទាំងធំ ហ្វឺត រួចដាក់សំណួរឱ្យសិស្ស ពិភាក្សាដូច ខាងក្រោម :

- តើប្អូនត្រូវធ្វើដូចម្តេចខ្លះក្នុងការជួយសិស្សមានបញ្ហាត្រចៀកដើម្បីឱ្យពួកគេអាចរៀនបានដូចសិស្សដទៃទៀត?

  ចម្លើយ

  ក- រៀបចំឱ្យអង្គុយតុមុខ ។

  ខ- ជួយបន្តអំណានពីគ្រូ ។

គ- ផ្តល់ឱកាសឱ្យសិស្សមានបញ្ហាត្រចៀកបានសួរ នូវអ្វីដែលវាស្តាប់ពុំបាន ។

- គ្រូបិទបង្ហាញក្រដាសផ្ទាំងធំនៅលើជញ្ជាំង រួចធ្វើការពិភាក្សាលើចម្លើយទាំងនោះ ។ ប្រសិនបើគំនិតយោបល់របស់សិស្សពុំបានបង្ហាញដូចចម្លើយខាងលើទេ អ្នកសម្របសម្រួលត្រូវបញ្ជាក់ចំណុចទាំងនោះបន្ថែម ។
- គ្រូរៀបសិស្សជាក្រុមតូចៗ រួចធ្វើការសម្តែងតួ តាមក្រុមនីមួយៗ ។ សិស្សបីនាក់ត្រូវជ្រើសរើសប្រធានបទមកសម្តែងតួដោយទាក់ទង នឹងសកម្មភាពជួយសិស្សមានបញ្ហាត្រចៀក ( សូមមើលប្រអប់លេខ១ )

| |
|---|
| ប្រអប់លេខ ១ ការសម្តែងតួសកម្មភាពជួយសិស្សមានបញ្ហាត្រចៀក |
| - គ្រូឱ្យសិស្សសរសេរតាមអាន ( ពីរ ឬ បីល្បះ ) |
| - គ្រូអានលើកទី១ |
| - សិស្សជាអ្នកជួយពិសេសអំណានបន្តលើកទី១ ពីគ្រូ |
| - គ្រូអានលើកទី២ |
| - សិស្សជាអ្នកជួយពិសេសអំណានបន្តលើកទី២ ពីគ្រូ |
| - គ្រូអានលើកទី៣ |
| - សិស្សជាអ្នកជួយពិសេស អំណានបន្តលើកទី៣ ពីគ្រូ |

បញ្ជាក់ៈបើសិនសិស្សមានបញ្ហាត្រចៀក២ទៅ ៣នាក់ ក្នុងមួយថ្នាក់យើងអាចរៀបសិស្សដែលជួយដើម្បីធ្វើការបន្តអំណានពីគ្រូតាមវិធីខាងលើ ។ បន្ទាប់ពីការសម្តែងតួនេះត្រូវបញ្ចប់ គ្រូគប្បីសង្ខេបយកគំនិតសំខាន់ៗនៃការសម្តែងតួ ហើយត្រូវបញ្ជាក់ឱ្យច្បាស់ថាៈសិស្សទាំងអស់គ្នាបានយល់ពីការប្រព្រឹត្តទៅនៃសកម្មភាពនេះ ។គ្រូអាចសួរសិស្សដោយប្រើសំណួរខាងក្រោម :

- តើប្អូនមានគំនិតយោបល់អ្វីផ្សេងទៀត សម្រាប់សកម្មភាពនេះ ?

- គ្រូត្រូវសរសេរសកម្មភាពនីមួយៗ ព្រមទាំងគំនិតយោបល់របស់សិស្សនៅក្តារខៀន រួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅ ។

# ឧបសម្ព័ន្ធ ឆ

# មេរៀននេះសម្រាប់ជួយកុមារអវត្តមានច្រើន

**I.** <u>សេចក្តីផ្តើម :</u>

មេរៀននេះអាចជួយគ្រូគ្រប់ថ្នាក់ ដើម្បីបង្រៀនសិស្សរបស់គេពីរបៀបជួយដល់សិស្សមានអវត្តមានច្រើនឱ្យបានមករៀន ដោយកាត់បន្ថយបានពីអវត្តមានច្រើន ហើយមករៀនបានទៀងទាត់ និងរៀនប្រកបដោយក្តីសប្បាយរីករាយ ។ បន្ទាប់ពីសិស្សគ្រប់ថ្នាក់ បានយល់ពីមេរៀននេះពួកគេអាចជួយដល់សិស្សមករៀនមានអវត្តមានច្រើនបានល្អប្រសើរ ។

**II.** <u>គោលបំណង :</u>

- សិស្សគ្រប់ថ្នាក់កំណត់បានពីបញ្ហាទាំងឡាយ ដែលកើតមានចំពោះសិស្សដែលរៀនមានអវត្តមានច្រើន។
- សិស្សគ្រប់ថ្នាក់ កំណត់យុទ្ធវិធីផ្សេងៗដើម្បីជួយសិស្សអវត្តមានច្រើន ឱ្យមករៀនបានទៀងទាត់។

**III.** <u>រយៈពេល :</u>

មេរៀននេះចំណាយពេល មួយ ម៉ោង សម្រាប់បង្រៀនសិស្សដែលត្រូវជួយសិស្សមានបញ្ហាអវត្តមានច្រើន។

**IV.** <u>សម្ភារៈ</u>

- ក្រដាសរ៉ាម A4
- ហ្វឺត
- ក្តារខៀន
- ដីស

V. <u>លំនាំបង្រៀន</u> :

គ្រូត្រូវពន្យល់ប្រាប់សិស្សថា សិស្សដែលមានបញ្ហាអវត្តមានច្រើនគឺភាគច្រើនពួកគេពុំបានទទួលលទ្ធផលល្អក្នុងការសិក្សាឡើយ។ ការកើនឡើងនៃអវត្តមាន ពីមួយខែទៅមួយខែ ធ្វើឱ្យការសិក្សារបស់គេកាន់តែរៀនខ្សោយទៅៗ ការថយចុះនៃការសិក្សានេះ អាចធ្វើឱ្យគេមានការធុញថប់នឹងការសិក្សា រហូតទៅដល់ខ្លាចសាលា ខ្លាចគ្រូ ខ្មាស់អៀន នឹងមិត្តភក្តិរហូតប្រឈមមុខសេចក្តីប្រថុយ នឹងការបោះបង់ ។ ដើម្បីជួយដោះស្រាយបញ្ហាខាងលើនេះ បានទាល់តែយើងទាំងអស់គ្នា ចូលរួមក្នុងសកម្មភាពកុមារជួយកុមារ ។ សកម្មភាពកុមារជួយកុមារគឺជា សកម្មភាពមួយដែលសិស្ស ២ នាក់ត្រូវជួយសិស្សអវត្តមានច្រើនម្នាក់ ។

- គ្រូចែកសិស្សជាក្រុមតូច ចែកក្រដាសផ្ទាំងធំ ហ្វឺត រួចសួរសំណួរដូចខាងក្រោម :

  តើប្អូនអាចធ្វើអ្វីបានខ្លះ ដើម្បីជួយមិត្តភក្តិរបស់ប្អូនដែលមានអវត្តមានច្រើន ?

  ចម្លើយ

  ក- ជួយបបួល ឬ ជួយនាំសិស្សដែលអវត្តមានច្រើន អោយមករៀនជារៀងរាល់ថ្ងៃ ។

  ខ- ជួយឧបកង់ បើសិនសិស្សនេះតូចហើយមានផ្ទះនៅឆ្ងាយពីសាលារៀន ។

គ- ត្រូវមានទំនាក់ទំនងល្អជាមួយសិស្សអវត្តមានច្រើន ។

ឃ- ជួយជំរុញសិស្សនេះឱ្យបានរៀនក្នុងក្លឹបសិក្សា ។

ង- ផ្តល់ឱកាសឱ្យពួកគេបានបញ្ចេញយោបល់ឱ្យបានច្រើនក្នុងពេលសិក្សា ។

- គ្រូឱ្យសិស្សបិទចម្លើយនៅលើជញ្ជាំង រួចធ្វើការពិភាក្សាលើចម្លើយទាំងនោះ ។ ប្រសិនបើគំនិតយោបល់របស់សិស្សពុំបានបង្ហាញដូចចម្លើយខាងលើទេ អ្នកសម្របសម្រួលត្រូវបញ្ជាក់ចំណុចទាំងនោះឱ្យសិស្ស ។
- គ្រូរៀបចំសិស្ស៤ទៅ៥នាក់ដើម្បីធ្វើការសម្តែងតួទាក់ទងនឹងសកម្មភាពបបួលសិស្សអវត្តមានច្រើនមករៀន ។ ប្រអប់លេខ ១

| |
|---|
| ប្រអប់លេខ ១ : ការសម្តែងតួ សកម្មភាពទាក់ទងការបបួលសិស្សអវត្តមានច្រើនឱ្យមករៀន |
| – ការសន្ទនានៅពេលជួបសិស្សអវត្តមានច្រើន( នៅផ្ទះ-ពេលសិស្សនេះកំពុងលេង... ។ល ។ ) |
| – ការពិភាក្សាគ្នានៅតាមផ្លូវ |
| – ធ្វើរបាយការណ៍ជូនគ្រូ |

- គ្រូគប្បីសង្ខេបយកគំនិតសំខាន់ៗ នៃការសម្តែងតួនីមួយៗ ហើយត្រូវបញ្ជាក់ឱ្យបានច្បាស់ថា សិស្សម្នាក់ៗ បានយល់ពីការប្រព្រឹត្តទៅនៃសកម្មភាពនេះ ។ គ្រូអាចសួរសិស្សដោយប្រើសំណួរខាងក្រោម :
  តើប្អូនមានគំនិតយោបល់អ្វីផ្សេងទៀតសម្រាប់សកម្មភាពជួយសិស្សអវត្តមានច្រើន ?
- គ្រូត្រូវសរសេរសកម្មភាពនីមួយៗ ព្រមទាំងគំនិតយោបល់របស់សិស្សនៅលើក្តារខៀន រួចឱ្យសិស្សចម្លងចូលសៀវភៅ ។
- គ្រូរៀបចំសិស្សមួយក្រុមទៀតធ្វើការសម្តែងតួនៅពេលទៅបបួលសិស្សនេះមិនបានមករៀនដោយជាប់រវល់ ឬមានជម្ងឺផ្សេងៗ ។ ប្រអប់លេខ២

| |
|---|
| ប្រអប់លេខ២ : ការសម្តែងតួពេលទៅបបួល សិស្សនេះមានការជាប់រវល់ ឬមានជម្ងឺផ្សេងៗ |
| – សម្តែងការគួរសម និងសន្ទនា នៅពេលជួបម្តាយ ឪពុកសិស្ស |
| – ការសន្ទនាជាមួយសិស្សនេះឈឺ ( សួរសុខទុក្ខ និង សម្តែងមនោសញ្ចេតនាផ្សេងៗ ) |
| – បណ្តាំផ្ញើ និងលាគ្នា |

- គ្រូគប្បីសង្ខេបយកគំនិតសំខាន់ៗ នៃការសម្តែងតួនីមួយៗ ហើយត្រូវបញ្ជាក់ឱ្យបានច្បាស់ថា សិស្សម្នាក់ៗ បានយល់ពីការប្រព្រឹត្តទៅនៃសកម្មភាពនេះ ។ គ្រូអាចសួរសិស្សដោយប្រើសំណួរខាងក្រោម :

- តើប្អូនមានគំនិតយោបល់អ្វីផ្សេងទៀតសម្រាប់សកម្មភាពជួយសិស្សអវត្តមានច្រើន ?

- គ្រូត្រូវសរសេរសកម្មភាពនីមួយៗ ព្រមទាំងគំនិតយោបល់របស់សិស្សនៅលើក្តារខៀន រួចឱ្យសិស្សចម្លងចូលសៀវភៅ ។